# ការចែករំលែកចំណេះដឹង និងទស្សនាអំពី

# *អភិបាលកិច្ចល្អ នីតិរដ្ឋ និងការផ្លាស់ប្តូរតវិយាបថជាវិជ្ជមាន*

រៀបចំ និងចែករំលែក ដោយ **ញាន សុមុន្និន្ទ**

អាជ្ញាកណ្តាលការងារ មជ្ឈត្តករពាណិជ្ជកម្ម អ្នកវិភាគគោលនយោបាយសេដ្ឋកិច្ច
និងអ្នកស្រាវជ្រាវផ្នែកអភិបាលកិច្ច-ការអភិវឌ្ឍ

# គោលដៅ

- ដើម្បីជួយដល់ ការតាក់តែង និងពិនិត្យផ្តល់យោបល់លើសេចក្តីព្រាងច្បាប់ លិខិតបទដ្ឋានគតិយុត្ត ប្រកបដោយសីលធម៌វិជ្ជាជីវៈ ផ្អែកលើលទ្ធផលនៃការស្រាវជ្រាវដែលមានលក្ខណៈជាប្រព័ន្ធ ធានាបាននូវអភិបាលកិច្ចល្អ និងនាំមកនូវការផ្លាស់ប្តូរឥរិយាបថជាវិជ្ជមាន។

# គោលបំណង

**គោលបំណងទី 1. ដើម្បីផ្ដល់ និងពង្រីកចំណេះដឹងអំពី**

- គោលការណ៍អភិបាលកិច្ចល្អ និងនីតិរដ្ឋ
- សីលធម៌វិជ្ជាជីវៈ និងគោលការណ៍សំខាន់ៗទាក់ទងនឹងការតាក់តែងពិនិត្យផ្ដល់យោបល់លើសេចក្ដីព្រាងច្បាប់លិខិតបទដ្ឋានគតិយុត្ត

**គោលបំណងទី 2. ដើម្បីជម្រុញឱ្យមន្ត្រីពាក់ព័ន្ធផ្ដល់តម្លៃ និងប្រើប្រាស់នូវរបៀបវារៈស្រាវជ្រាវ រ៉កស៊ីពី** (ROCCIPI research agenda) សម្រាប់ជំនួយដល់ការតាក់តែងពិនិត្យផ្ដល់យោបល់លើសេចក្ដីព្រាងច្បាប់លិខិតបទដ្ឋានគតិយុត្ត ផ្អែកលើហេតុពិតជាក់ស្ដែង និងភាពឡូស៊ិចសម្រាប់ដោះស្រាយបញ្ហា និងនាំមកនូវការផ្លាស់ប្ដូរឥរិយាបថជាវិជ្ជមាន។

បើគ្មានថវិកាសម្រាប់ចែករំលែក ចូរខិតខំចែករំលែកចំណេះដឹង និងសិក្សាស្វែងយល់គ្រប់ពេលវេលា!!

ចូររស់ដើម្បីរៀន ហើយរៀនមួយជីវិតដើម្បីរស់ ចែករំលែកដើម្បីរស់ ហើយរស់នៅដើម្បីចែករំលែក

ចូរញុាំដើម្បីរស់ ប៉ុន្តែសូមកុំរស់ដើម្បីញុាំ!!

ចំណេះដឹង គុណធម៌ សុជីវធម៌ សច្ចធម៌ និងសប្បុរសធម៌ ឬ ការបរិច្ចាគ ដោយមិនរំពឹងនូវការតបស្នងសងគុណ ឬ ផលប្រយោជន៍នយោបាយសេដ្ឋកិច្ចត្រឡប់មកវិញ គឺជាគុណតម្លៃមហាសាលរបស់មនុស្ស។

# ប្រធានបទ

- [illegible]

1. និយមន័យនៃច្បាប់
2. គោលការណ៍ច្បាប់សំខាន់ៗ
3. ឋានានុក្រមនៃច្បាប់កម្ពុជា
4. សីលធម៌វិជ្ជាជីវៈរបស់អ្នកតាក់តែងពិនិត្យផ្តល់យោបល់លើសេចក្តីព្រាងច្បាប់ លិខិតបទដ្ឋានគតិយុត្ត

# ប្រធានបទ

- v ៚ មា ៥ ័ ១៥ ុ ឆ្ក ៧ ឥ ៦០ ឬ ័ ២ ្រ

  5. គោលការណ៍នៃអភិបាលកិច្ចល្អ

  6. គោលការណ៍ជាមូលដ្ឋាននៃនីតិរដ្ឋ

  7. អត្ថន័យនៃការផ្លាស់ប្តូរឥរិយាបថជាវិជ្ជមាន

  8. វិធីសាស្ត្រនិងគោលបំណងនៃការដោះស្រាយបណ្តឹងតវ៉ា-វិវាទក្រៅប្រព័ន្ធតុលាការ

# ប្រធានបទ

- **គោលការណ៍ និងតម្រូវការនៃការតាក់តែងពិនិត្យច្បាប់សម្រាប់អភិបាលកិច្ចល្អ និងការផ្លាស់ប្តូរវិជ្ជមាន**

9. បទប្បញ្ញត្តិរដ្ឋធម្មនុញ្ញទាក់ទងនឹងគោលការណ៍សម្រាប់ការធ្វើច្បាប់

10. គោលបំណង កត្តាប្រឈម តម្រូវការ វិធីសាស្ត្រ និងទិចនិកនៃការតាក់តែងច្បាប់

11. សំណួរផ្នែកនីតិរដ្ឋសម្រាប់ការពិនិត្យលើសេចក្តីព្រាងច្បាប់លិខិតបទដ្ឋានគតិយុត្តដើម្បីធានាបាននូវអភិបាលកិច្ច

# ប្រធានបទ

- **គោលការណ៍ និងតម្រូវការនៃការតាក់តែងពិនិត្យច្បាប់សម្រាប់អភិបាលកិច្ចល្អ និងការផ្លាស់ប្តូរឥរិយាបថជាវិជ្ជមាន**

12. នីតិវិធីនៃការតាក់តែងច្បាប់របស់អង្គប្រតិបត្តិ តាមសារាចរណែនាំ លេខ ០៣ (២០១៣) ស្តីពីនីតិវិធី និងវិធាននៃការតាក់តែងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត

13. របាយការណ៍ស្រាវជ្រាវ រ៉កស៊ីពី (ROCCIPI) សម្រាប់ជំនួយដល់ការតាក់តែងពិនិត្យផ្តល់យោបល់លើសេចក្តីព្រាងច្បាប់លិខិតបទដ្ឋានគតិយុត្ត ដើម្បីនាំមកនូវការផ្លាស់ប្តូរឥរិយាបថជាអវិជ្ជមាន

14. ទម្លាប់អនុវត្ត និងបញ្ហាប្រឈមនានាក្នុងការតាក់តែងច្បាប់នៅកម្ពុជាបច្ចុប្បន្ន។

## តើអ្នកចាប់អារម្មណ៍លើប្រធានបទណាខ្លះ?

# 1. និយមន័យនៃច្បាប់

តើអ្នកជឿឬទេថា ការយល់ដឹងច្បាស់

អំពីអត្ថន័យនៃច្បាប់ និង

សារៈសំខាន់នៃច្បាប់ចំពោះសង្គម

នឹងជួយអ្នកតាក់តែងច្បាប់ សរសេរនូវ

ច្បាប់ដែលសង្គមចង់បាន?

តើដូចម្ដេចហៅថា “ច្បាប់”?
តើអាចរកសេចក្ដីពន្យល់ពាក្យនេះនៅទីណា?

<u>ពាក្យថា  ច្បាប់   ក្នុងន័យទូលាយ និងន័យចង្អៀត</u>

# ពាក្យថា ច្បាប់ ក្នុងន័យទូលាយ និងន័យចង្អៀត

- វចនានុក្រមច្បាប់ របស់ ថៅក្រម ហ៊ីង ធីឫទ្ធិ ពន្យល់ថា **ច្បាប់ (loi, law)** វិធានជាលាយល័ក្ខអក្សរដែលរដ្ឋសភាបានអនុម័ត ហើយប្រកាសឱ្យប្រើដោយព្រះរាជក្រម ឬក្រឹត្យ។ តាមន័យទូលាយ ច្បាប់ជាវិធានរបស់សង្គមជាតិដែលអាជ្ញាធរមានសមត្ថកិច្ចតាក់តែងឡើងឱ្យពលរដ្ឋទាំងអស់ស្ថិតនៅក្រោមអំណាចនៃច្បាប់នោះ។

• វចនានុក្រមខ្មែរ (របស់សម្ដេច ជួន ណាត) ពន្យល់ថា **ច្បាប់** ជាសេចក្ដីបញ្ញត្តិ សម្រាប់អ្នកនគរ ប្រតិបត្តិតាម។ វិន័យ ក្រឹត្យក្រម ក្បួនប្រដៅមនុស្សឱ្យប្រព្រឹត្តិល្អ។

- សទ្ទានុក្រមនៃច្បាប់ភូមិបាល ឆ្នាំ២០០១ ពន្យល់ថា

  **ច្បាប់** (loi) ជាលិខិតបទដ្ឋានគតិយុត្ត ដែលអនុម័តដោយអង្គនីតិបញ្ញត្តិ (សភា) និងចូលជាធរមាន តាមរយៈព្រះរាជក្រម ប្រកាសអោយប្រើ។

- ពាក្យថា **បទដ្ឋានគតិយុត្ត** (legal norm, norme jurisdique/regle de droit) ក្នុងសទ្ទានុក្រមនៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ ចំនុចទី ៨៥ សំដៅដល់

  - **វិធានច្បាប់** ដូចជា ច្បាប់ និងបទបញ្ញាផ្សេងៗ ដែលបានបង្កើតដោយរដ្ឋ

  - **វិធានច្បាប់** ដែលនាំឱ្យមានតម្លៃបង្ខិតបង្ខំ (តម្រូវឱ្យអនុត្តតាម) ទោះបីចេញពីប្រភពណាក៏ដោយ (ច្បាប់  សន្ធិសញ្ញា …)

# វចនានុក្រម Black´s Law Dictionary

## ច្បាប់ មាននិយមន័យជាច្រើន

*(១) ច្បាប់គឺជារបបមួយដែលបញ្ជាលើសកម្មភាព និងទំនាក់ទំនងរបស់មនុស្ស តាមរយៈ ការប្រើក្នុងលក្ខណៈជាប្រព័ន្ធនូវកម្លាំងរបស់សង្គមមួយដែលបានរៀបចំជាអង្គការចាត់តាំងនយោបាយ ឬ តាមរយៈសម្ពាធសង្គម គាំទ្រដោយកម្លាំងដែលមានក្នុងសង្គមនោះ*

(២) ច្បាប់គឺជាបន្ទុំនៃនីតិ ប្រេស៊ីឌិនរបស់ចៅក្រម និង គោលការណ៍គតិយុត្តដែលគេបានទទួលយក; ជាបន្ទុំនៃមូលដ្ឋានសិទ្ធិអំណាចសម្រាប់គាំទ្រដល់ សកម្មភាពរបស់រដ្ឋបាល និងរបស់តុលាការ

(៣) ច្បាប់ គឺជាសំណុំនៃវិធាន ឬ គោលការណ៍ ទាក់ទងនឹង ផ្នែកជាក់លាក់នៃប្រព័ន្ធច្បាប់

(៤) ច្បាប់ គឺជាដំណើការរដ្ឋបាល និងតុលាការ; ជាសកម្មភាព និងដំណើការផ្លូវច្បាប់ <នៅពេលដែលការចរចារអំពីដំណោះស្រាយចំពោះវិវាទណាមួយមិនបានជោគជ័យ គូភាគីក៏ដាក់វិវាទរបស់ខ្លួនជូនច្បាប់>

(៥)ច្បាប់ គឺជាលក្ខន្តិកៈ <សភាបានអនុម័តច្បាប់>

## ចំណាំ:

- ពាក្យមួយ អាចមានន័យខុសគ្នា ក្នុងច្បាប់ផ្សេងគ្នា អាស្រ័យលើការកំណត់ក្នុងច្បាប់នោះ។

# ប្រភពគំនិតនៃច្បាប់

- **គំនិតអាជ្ញាបញ្ញា** (Imperative Idea)៖ ជាគំនិតដែលថា វិធាន ត្រូវបានដាក់ចេញដោយស្ថាប័នធ្វើច្បាប់នៃសង្គមដែលមានការរៀបចំអង្គការចាត់តាំងនយោបាយ ដែលទទួលបាននូវកម្លាំងអានុភាពចេញពីអំណាចអធិរាជ្យ។

# ប្រភពគំនិតនៃច្បាប់

- **គំនិតសមហេតុផល ឬ សីលធម៌** (Rational or Ethical idea)៖ ជាគំនិតដែលថា វិធាននៃសិទ្ធិ និងយុត្តិធម៌ ទទួលបានសិទ្ធិអំណាចចេញពីភាពសមហេតុសមផលនៃវិធាននោះ ឬ ភាពអនុលោមតាមទស្សននៃសិទ្ធិ ហើយដែលគ្រាន់តែមានទទួលស្គាល់ ប៉ុន្តែមិនមែនត្រូវបានតាក់តែងឡើងដោយអំណាចអធិរាជ្យ ទេ។

ជាអ្នកតាក់តែងច្បាប់ ឬ អ្នកធ្វើច្បាប់ តើអ្នកប្រកាន់យកគំនិតនៃច្បាប់មួយណា : **គំនិតអាជ្ញាបញ្ញា ឬ គំនិតសមហេតុផល/សីលធម៌ ?**

# ហេតុអ្វីបានជាសង្គមត្រូវការច្បាប់?

# ហេតុអ្វីបានជាសង្គមត្រូវការច្បាប់?

- សង្គមមានគ្នាពីរបីនាក់ មិនចាំបាច់មានច្បាប់ទេ
- សង្គមមានសមាជិកច្រើន និងអន្តរទំនាក់ទំនងជាមួយសង្គមផ្សេងទៀត ទង្វើនៃសមាជិកសង្គមមួយ អាចប៉ះពាល់ដល់សង្គមមួយទៀត អាចនាំឱ្យមានជម្លោះស្លាប់រស់ និងបាត់សណ្តាប់ធ្នាប់សង្គម ឬ ប៉ះពាល់ដល់ទំនាក់ទំនងល្អរវាងសង្គមផ្សេងៗ

# ហេតុអ្វីបានជាសង្គមត្រូវការច្បាប់?

- ដូច្នេះ ត្រូវការឱ្យមានវិធានច្បាប់សម្រាប់គ្រប់គ្រងទង្វើរបស់មនុស្សក្នុងសង្គម ដែលបង្ខំឱ្យគោរពអនុវត្តតាម បើមិនដូច្នោះទេត្រូវទទួលរង ទោសពិន័យ ឬ ទណ្ឌកម្ម ជាការព្រមានដល់សមាជិកផ្សេងទៀត។

# សំណួរ:

- តើអ្នកយល់ដូចម្តេចនៅពេលគេនិយាយថា ប្រទេសមួយមានច្បាប់ ឬ ឥតច្បាប់? ពេលគេនិយាយថាគ្មានច្បាប់គ្រប់គ្រងលើបញ្ហាជាក់លាក់ណាមួយ?

ចូរពន្យល់ពីអត្ថន័យនៃពាក្យថា “ច្បាប់” ដោយប្រើពាក្យសម្តីផ្ទាល់របស់អ្នក

# 2. គោលការណ៍ច្បាប់សំខាន់ៗ

## (1) នៅកម្រិតអន្តរជាតិ

សន្ធិសញ្ញា និងកិច្ចព្រមព្រៀងអន្តរជាតិខ្លះ ដែលចុះហត្ថលេខា ឬ ផ្តល់សច្ចាប័នដោយប្រទេសមួយ អាចមានអំណាចអានុភាពខ្ពស់ជាងច្បាប់ជាតិរបស់ប្រទេសនោះ រួមទាំង រដ្ឋធម្មនុញ្ញ របស់ប្រទេសនោះផងដែរ។

(២) នៅកម្រិតជាតិ

ប្រទេសភាគច្រើនអនុម័តនូវរដ្ឋធម្មនុញ្ញជាច្បាប់កំពូលរបស់ប្រទេស ដែលច្បាប់ លិខិតបទដ្ឋានគតិយុត្តផ្សេងៗ ឬ សេចក្តីសម្រេចនានា ចេញដោយស្ថាប័នរដ្ឋ ចាំបាច់ត្រូវតែអនុលោមតាមរដ្ឋធម្មនុញ្ញ។

(៣) ច្បាប់ពិសេស មានអានុភាពខ្ពស់ជាង ច្បាប់ទូទៅ

(៤)ច្បាប់ដែលអនុម័តដោយអង្គនីតិបញ្ញត្តិ ត្រូវមាន ឋានានុក្រមខ្ពស់ជាង លិខិតបទដ្ឋានគតិយុត្ត ចេញ ឬ កំណត់ដោយ អង្គប្រតិបត្តិ ឬ ស្ថាប័នតុលាការ ឬ ស្ថាប័នផ្សេងទៀត។

(៥) ជាទូទៅ ប្រព័ន្ធច្បាប់របស់ប្រទេសមួយ តែងតែ កំណត់នូវអាជ្ញាយុកាលនៃការទទួលខុសត្រូវចំពោះ អំពើជាក់លាក់មួយ (រដ្ឋប្បវេណី និងព្រហ្មទណ្ឌ)។

(៦) ប្រទេសជាច្រើនអនុម័តនូវគោលការណ៍នៃការបែងចែកអំណាចដាច់ចេញពីគ្នានៃអំណាចទាំងបីរបស់រដ្ឋ គឺ អំណាចនីតិបញ្ញត្តិ អំណាចប្រតិបត្តិ និងអំណាចតុលាការ។

- ប៉ុន្តែ វាមិនមែនមានន័យថា ប្រព័ន្ធច្បាប់ទាំងមូលរបស់ប្រទេសនោះ ចាំបាច់ត្រូវតែបង្កើតឡើង ឬអនុម័តដោយអង្គនីតិបញ្ញត្តិនោះទេ។

- មានន័យថា ប្រសិនបើចាំបាច់ អង្គផ្សេងៗទៀត ដូចជា អង្គប្រតិបត្តិ អាចចេញនូវគោលការណែនាំ ឬ វិធានច្បាប់ ឬ បទបញ្ជាជាបទដ្ឋានគតិយុត្តសម្រាប់អនុវត្តក្នុងអំឡុងពេលអន្តរកាល ឬ ផ្អែកលើការធ្វើប្រតិភូកម្មអំណាចក្នុងការធ្វើវិធានណែនាំលម្អិតសម្រាប់អនុវត្តច្បាប់ដែល អនុម័តដោយសភាបាន។

(៧) ច្បាប់ថ្មី ឬ បទប្បញ្ញត្តិថ្មីស្តីពីពីបញ្ហាដូចគ្នា និរាករនូវច្បាប់ចាស់ ឬ បទប្បញ្ញត្តិចាស់ សម្រាប់ទង្វើដែលបានប្រព្រឹត្តក្រោយច្បាប់ថ្មី ឬ បទប្បញ្ញត្តិថ្មីចូលជាធរមាន ឬ មានអានុភាពអនុវត្ត (គេហៅថាគោលការណ៍អប្រតិសកម្មនៃច្បាប់)។

- ប៉ុន្តែករណីមានចែងជាក់លាក់ ច្បាប់ ឬ បទប្បញ្ញត្តិថ្មីនោះ ក៏អាចយកទៅអនុវត្តចំពោះទង្វើដែលបានប្រព្រឹត្តមុនពេលមានច្បាប់ ឬ បទប្បញ្ញត្តិនោះផងដែរ (គេហៅថា ការអនុវត្តប្រតិសកម្ម)។

(៨) គ្មាននរណាអាចទាមទារថាខ្លួនមិនដឹងថាមានច្បាប់ដើម្បីឱ្យរួចផុតពីការទទួលខុសត្រូវដែលចែងក្នុងច្បាប់នោះទេ។

- ប៉ុន្តែ ជាផ្នែកមួយនៃ អភិបាលកិច្ចល្អ រដ្ឋត្រូវតែផ្សព្វផ្សាយឱ្យបានទូលំទូលាយ នូវរាល់ច្បាប់ទាំងអស់ ក្នុងទម្រង់មួយដែលងាយយល់ និងប្រសិនបើអាចធ្វើបានគួរមានសេចក្តីពន្យល់លម្អិត ឬ សេចក្តីបកស្រាយខ្លឹមសារនៃច្បាប់ ឬ បទប្បញ្ញត្តិទាំងឡាយផង។

(៩) ករណីដែលគ្មានច្បាប់ចែងហាមឃាត់នូវទង្វើណាមួយ បុគ្គលគ្រប់រូប អាចប្រព្រឹត្តអំពើនោះបានដោយសេរី ដោយមិនចាំបាច់មានការអនុញ្ញាតពីបុគ្គល ឬស្ថាប័នណាឡើយ។

(១០) គោលការណ៍នៃភាពស្មើគ្នាចំពោះមុខច្បាប់។

(១១) គោលការណ៍នៃការសន្មត់សច្ចធា រហូតដល់ត្រូវបាន តុលាការមានសមត្ថកិច្ចវិនិច្ឆ័យ។

(១២) ច្បាប់អន្តរជាតិអាចជាមូលដ្ឋាននៃការទាមទាររបស់ប្រពលរដ្ឋនៃប្រទេសមួយ នៅពេលដែលច្បាប់ជាតិចែងទទួលស្គាល់ និងការពារសិទ្ធិដែលចែងក្នុងច្បាប់អន្តរជាតិនោះ បើមិនដូច្នោះទេ ច្បាប់អន្តរជាតិនោះជាទូទៅគ្រាន់តែចងកាតព្វកិច្ចចំពោះរដ្ឋដែលជាហត្ថលេខីប៉ុណ្ណោះ។

- ប៉ុន្តែពាក់ព័ន្ធនឹងបញ្ហាសិទ្ធិមនុស្ស ក្រុមប្រឹក្សាធម្មនុញ្ញ បានធ្វើការបកស្រាយរដ្ឋធម្មនុញ្ញ ណែនាំដល់តុលាការឱ្យយកចិត្តទុកដាក់អំពីច្បាប់អន្តរជាតិស្តីពីសិទ្ធិមនុស្ស។

តើអ្នកយល់យ៉ាងណាចំពោះការណែនាំនេះ?

# តើអ្នកយល់យ៉ាងដូចម្តេចអំពីបទប្បញ្ញត្តិមាត្រា ៣១ និង មាត្រា ៨ នៃរដ្ឋធម្មនុញ្ញ ដែលចែងដូចតទៅ:

- **មាត្រា ៣១:** ព្រះរាជាណាចក្រកម្ពុជា ទទួលស្គាល់ និងគោរពសិទ្ធិមនុស្ស ដូចមានចែងក្នុងធម្មនុញ្ញ នៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញា ព្រមទាំង អនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ។
- **មាត្រា ៨:** ព្រះមហាក្សត្រ … ទ្រង់ជាអ្នកធានាការគោរពសិទ្ធិ និងសេរីភាពរបស់ប្រជាពលរដ្ឋ និងការគោរពសន្ធិសញ្ញាអន្តរជាតិ។

# 3. ឋានានុក្រមនៃច្បាប់កម្ពុជា

- ដូចម្តេច ហៅថា ឋានានុក្រមច្បាប់?
- តើប្រភេទលិខិតូបករណ៍គតិយុត្តរបស់កម្ពុជាមានអ្វីខ្លះ?
- <u>ចូរពិភាក្សាអំពីឋានានុក្រមនៃច្បាប់កម្ពុជា</u>

# ឋានានុក្រមច្បាប់កម្ពុជា ពីខ្ពស់ទៅទាប

1. រដ្ឋធម្មនុញ្ញ និងច្បាប់ធម្មនុញ្ញ (ដែលធ្វើវិសោធនកម្ម ឬ កែសម្រួលបទប្បញ្ញត្តិនៃរដ្ឋធម្មនុញ្ញ) (ជាច្បាប់កំពូលរបស់ប្រទេសកម្ពុជា)
2. ច្បាប់ ឬ ក្រម ដែលអនុម័តដោយសភាជាតិ និងត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រម
3. ព្រះរាជក្រឹត្យ
4. អនុក្រឹត្យ
5. បទបញ្ជារាជរដ្ឋាភិបាល ឬ សារាចរណ៍ណែនាំរបស់រាជរដ្ឋាភិបាល
6. ប្រកាស ប្រកាសរួម ប្រកាសអន្តរក្រសួង
7. សារាចរណ៍ណែនាំអនុវត្ត ឬ សេចក្ដីណែនាំអនុវត្តរបស់ក្រសួងស្ថាប័ន
8. សេចក្ដីសម្រេចស្ដីពីគោលការណ៍ណែនាំអនុវត្ត ឬ សៀវភៅណែនាំអនុវត្តរបស់ក្រសួងស្ថាប័ន
9. សេចក្ដីសម្រេចរបស់រាជរដ្ឋាភិបាល ឬ ទីស្ដីការគណៈរដ្ឋមន្ត្រី
10. សេចក្ដីសម្រេចផ្សេងៗរបស់ក្រសួងស្ថាប័ន
11. ដីកាសម្រេចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
12. លិខិតជូនដំណឹង ឬ សេចក្ដីជូនដំណឹងរបស់រាជរដ្ឋាភិបាល ឬ ទីស្ដីការគណៈរដ្ឋមន្ត្រី
13. លិខិតជូនដំណឹង ឬ សេចក្ដីជូនដំណឹងរបស់ក្រសួង ស្ថាប័ន។

# 4. អត្ថន័យនៃការតាក់តែងច្បាប់ តួនាទី និងក្រមសីលធម៌ របស់អ្នកតាក់តែងពិនិត្យផ្តល់យោបល់លើច្បាប់

## អត្ថន័យ - ការតាក់តែងច្បាប់

ជា ការសរសេរនូវវិធានក្នុងទម្រង់ជាច្បាប់ ឬ លិខិតបទដ្ឋានគតិយុត្ត ឬ គោលការណ៍ណែនាំផ្នែកនីតិវិធី ឬ ផ្នែកបច្ចេកទេសលក្ខន្តិកៈ ឬ កិច្ចព្រមព្រៀងចងកាតព្វកិច្ចចំពោះសង្គម ដែលគ្របដណ្តប់លើបញ្ហាមួយជាក់លាក់ឬ លើបញ្ហាទូលំទូលាយ។

តើនិយមន័យបែបណាដែលអ្នកចង់ផ្តល់ឱ្យចំពោះពាក្យនេះ?

# ចំណេះដឹងមូលដ្ឋានសម្រាប់ការតាក់តែងច្បាប់

ចំណេះដឹងអំពី

- រចនាសម្ព័ន្ធស្ថាប័ន បរិបទ ក្របខណ្ឌគោលនយោបាយ និងច្បាប់ជាធរមាន
- គោលនយោបាយ និងវិធានការនានាសម្រាប់ដោះស្រាយបញ្ហា ឬ
- បញ្ហាដែលត្រូវចែងដោះស្រាយនៅក្នុងសេចក្តីព្រាងលិខិតូបករណ៍គតិយុត្ត

# តួនាទីរបស់អ្នកតាក់តែងច្បាប់ក្នុងដំណើការធ្វើច្បាប់

- ដាក់ ឬ បំលែងគោលនយោបាយចូលទៅក្នុងសេចក្តីព្រាង ឬ សេចក្តីស្នើច្បាប់ ដែលចែងទុកជាមុននូវតវិយាបទជាក់លាក់ និងលម្អិត ដែលទាមទារឱ្យមានសម្រាប់ដោះស្រាយបញ្ហាសង្គមដែលគោលនយោបាយមានបំណងចង់ដោះស្រាយ និង
- តាក់តែងសេចក្តីព្រាង ឬ សេចក្តីស្នើច្បាប់ក្នុងទម្រង់មួយដែលមានលក្ខណៈច្បាស់លាស់ ជាក់លាក់ ងាយយល់ និងអាចប្រើប្រាស់បាន។

**ក្នុងប្រទេសកំពុងអភិវឌ្ឍន៍ និងអន្តរកាល (កម្ពុជា) គួរយល់ដឹងផងនូវបញ្ហាសំខាន់ពីរ គឺ:**

1. ភាពក្រីក្រ និងភាពងាយរងគ្រោះ និង
2. ការធ្វើសេចក្តីសម្រេចរបស់រដ្ឋាភិបាលមានអភិបាលកិច្ចទុនខ្សោយ

   (ក) កម្មវិធីអភិវឌ្ឍន៍របស់រដ្ឋគ្មានប្រសិទ្ធភាពក្នុងការបង្កើននូវឱកាសការងារមានផលិតភាព និងគុណភាពនៃជីវិតរបស់អ្នកក្រដែលជាក្រុមមនុស្សភាគច្រើន និង

   (ខ) ការធ្វើសេចក្តីសម្រេចបែបអនាធិបតេយ្យតាមចិត្ត (និងពេលខ្លះប្រកបដោយភាពពុករលួយ)។ ការធ្វើសេចក្តីសម្រេចរបស់រដ្ឋបែបអនាធិបតេយ្យ ឆ្លុះបញ្ចាំងឱ្យឃើញពីអវត្តមាននូវសមាសធាតុមួយ ឬ ច្រើននៃអភិបាលកិច្ចល្អ។

# សីលធម៌វិជ្ជាជីវៈរបស់ អ្នកតាក់តែងពិនិត្យផ្តល់យោបល់លើច្បាប់

- គួរបំពេញមុខងារជាអ្នករក្សាការពារនូវនីតិរដ្ឋ ដើម្បីធានានូវអភិបាលល្អ និងជៀសវាងនូវការធ្វើសេចក្តីសម្រេចបែបអនាធិបតេយ្យ
- គួរការពារផលប្រយោជន៍សាធារណៈ ភក្តីចំពោះដំណើរការធ្វើច្បាប់ និងចំពោះអង្គនីតិបញ្ញត្តិ (រដ្ឋាភិបាលជាអតិថិជនរបស់អ្នកតាក់តែងច្បាប់)
- គួរមានសមត្ថភាពក្នុងការបំលែងគោលនយោបាយឱ្យក្លាយជានីតិមួយដែលអាចអនុវត្តបានយ៉ាងមានប្រសិទ្ធភាព

- គួររក្សាភាពសម្ងាត់សម្រាប់តែគោលបំណងជាក់ស្ដែងក្នុងការធ្វើការងារយ៉ាងជិតស្និទ្ធជាមួយក្រសួងស្ថាប័ននានា
- មិនត្រូវតាក់តែងច្បាប់ក្នុងលក្ខណៈដែលបំពានលើផលប្រយោជន៍ទូទៅ ឬ ផលប្រយោជន៍សាធារណៈឡើយ
- គួរលើកកំពស់នីតិរដ្ឋ និងឯករាជ្យភាពនៃអ្នកតាក់តែងច្បាប់
- មិនគួរតាក់តែងច្បាប់ផ្ទុយនឹងជំនឿប្ដេជ្ញាផ្ទាល់ខ្លួនឡើយ។

# គោលការណ៍ ឬ ស្តង់ដារ
# ដែលអ្នកតាក់តែងពិនិត្យផ្តល់យោបល់លើច្បាប់ គួរគោរព

អ្នកតាក់តែងពិនិត្យផ្តល់យោបល់លើច្បាប់ ប្រកបដោយវិជ្ជាជីវៈ និងក្រមសីលធម៌ គួរតែប្រើប្រាស់នូវគោលការណ៍ ឬ ស្តង់ដារខាងក្រោមនេះ

1. ការធានានូវធម្មនុញ្ញភាព (ឧត្តមានុភាពនៃច្បាប់)
2. គ្មានអានុភាពប្រតិសកម្ម (លើកលែងតែ ឧក្រិដ្ឋកម្មអន្តរជាតិ ឬ ការកាត់បន្ថយនូវបន្ទុក ឬ កាតព្វកិច្ចជាធរមានរបស់ប្រជាពលរដ្ឋ)
3. ទម្រង់ស្តង់ដារនៃសេចក្តីព្រាងច្បាប់ ឬ សេចក្តីស្នើច្បាប់

4. ភាពច្បាស់លាស់នៃរាល់ទណ្ឌកម្ម ទោសពិន័យ និង ឧបាស្រ័យទាំងឡាយ

5. ការធ្វើប្រតិភូកម្មច្បាស់លាស់នូវ អំណាចរដ្ឋបាលបែបឆន្ទានុសិទ្ធិ ដែលអាចវាស់វែងបាន មិនមែនឥតព្រំដែន

6. ការធានានូវបូរណភាពផ្ទៃកច្បាប់ដោយមិនឱ្យមានទំនាស់ ភាពគងជាន់គ្នា ឬ ភាពឥតចាំបាច់នៃច្បាប់ដែលមានជាធរមាន

7. សេចក្តីថ្លែងច្បាស់លាស់ និងគ្រប់ជ្រុងជ្រោយអំពី

- គោលបំណង ដើម្បីជម្រាបដល់ប្រជាពលរដ្ឋពីហេតុផលសម្រាប់សេចក្តីព្រាងច្បាប់ ឬ សេចក្តីស្នើច្បាប់
- បញ្ហាទាំងឡាយដែលមានបំណងដោះស្រាយតាមសេចក្តីព្រាងច្បាប់ ឬ សេចក្តីស្នើច្បាប់នោះ និង
- ទំនាក់ទំនងនៃសេចក្តីព្រាងច្បាប់ ឬ សេចក្តីស្នើច្បាប់ជាមួយនឹងច្បាប់ទាំងឡាយដែលមានជាធរមាន។

# 5. គោលការណ៍នៃអភិបាលកិច្ចល្អ

- តើអ្វីហៅថា អភិបាលកិច្ចល្អ?
- សមាសធាតុគន្លឹះៗនៃអភិបាលកិច្ចល្អមានអ្វីខ្លះ?

# សមាសធាតុគន្លឹះៗនៃអភិបាលកិច្ចល្អ

1. **គណនេយ្យភាព** (ចំពោះថ្នាក់លើ និងចំពោះថ្នាក់ក្រោម) របស់មន្ត្រីរដ្ឋាភិបាល
2. **តម្លាភាព**នៃសេចក្តីសម្រេចរបស់រដ្ឋាភិបាល
3. **ការចូលរួម**របស់ភាគីពាក់ព័ន្ធក្នុងដំណើការនៃការធ្វើសេចក្តីសម្រេចរបស់រដ្ឋាភិបាលដែលប៉ះពាល់ដល់ពួកគេ
4. **សេចក្តីសម្រេច**របស់រដ្ឋាភិបាលធ្វើឡើងផ្អែក**តាមវិធានច្បាប់**ជាជាងតាមប្រាថ្នារបស់មន្ត្រី ឬ អ្នកនយោបាយ។

# 6. គោលការណ៍ជាមូលដ្ឋាននៃនីតិរដ្ឋ

## នីតិរដ្ឋ (rule of law)

- មាននិយមន័យច្រើន (បើចង់ដឹងខ្ញុំអាចផ្តល់សេចក្តីលម្អិតបន្ថែមបាន)
- មិនមែនចាំបាច់មានន័យដូចការគ្រប់គ្រងដឹកនាំតាមច្បាប់ទេ (rule by law)
- មានន័យខុសគ្នាទាំងស្រុងពីការគ្រប់គ្រងដឹកនាំដោយបុគ្គល (rule of man) ឬ មនុស្សមួយក្រុមតូចដែលពោរពេញដោយផលប្រយោជន៍ផ្ទាល់ខ្លួន (vested interest)

## ការគ្រប់គ្រងដឹកនាំដោយច្បាប់ (rule by law)

- គ្រាន់តែតម្រូវឱ្យអង្គភាពមានសមត្ថកិច្ច ឬ ថៅក្រម ធ្វើសេចក្តីសម្រេច លើករណីវិវាទដោយផ្អែកលើបទប្បញ្ញត្តិច្បាប់ជាធរមាន ដោយមិនខ្វល់ថា បទប្បញ្ញត្តិនោះ ត្រូវបានតាក់តែងឡើងយ៉ាងដូចម្តេច ឬ ប៉ះពាល់ដល់សមាជិកផ្សេងទៀតនៃសង្គមបែបណានោះទេ។

# គោលការណ៍ ៦ យ៉ាងនៃនីតិរដ្ឋ

1. ឧត្តមានុភាពនៃច្បាប់ (រដ្ឋធម្មនុញ្ញ ឬ ច្បាប់អន្តរជាតិពាក់ព័ន្ធ)
2. ការបែងចែកអំណាចដាច់ពីគ្នា
3. ការការពារអាយុជីវិត សេរីភាព សុវត្ថិភាព និងទ្រព្យសម្បត្តិរបស់បុគ្គល
4. ភាពច្បាស់លាស់ពិតប្រាកដនៃច្បាប់
5. ភាពស្មើគ្នាចំពោះមុខច្បាប់
6. នីតិរដ្ឋតាមភាពជាក់ស្តែង (មិនមែនក្នុងទ្រឹស្តី)

# សំណួរដើម្បីកំណត់ថាមាន នីតិរដ្ឋ ឬអត់ (ស្តង់ដារនីតិរដ្ឋ)

(១) តើច្បាប់ទាំងឡាយមានលក្ខណៈជាសាធារណៈ ឬទេ? តើប្រជាពលទាំងអស់មានឱកាសក្នុងដឹងថាច្បាប់ចែងយ៉ាងម៉េច ឬ តម្រូវឱ្យធ្វើអ្វីខ្លះឬទេ?

(២) តើច្បាប់ទាំងឡាយត្រូវបានសរសេរយ៉ាងច្បាស់លាស់ ដែលមានអត្ថន័យច្បាស់ ហើយគេអាចប៉ាន់ស្មានបានអំពីផលវិបាកនៃការអនុវត្តច្បាប់នោះឬទេ?

(៣) តើថៅក្រម ឥតលម្អាង និងឯករាជ្យ ឬទេ?

(៤) តើប្រជាពលរដ្ឋទាំងឡាយត្រូវបានគេប្រព្រឹត្តចំពោះខ្លួនស្មើគ្នាក្រោមច្បាប់ទាំងឡាយ ឬ តើច្បាប់ទាំងឡាយអនុវត្តចំពោះតែបុគ្គល ឬ វណ្ណៈមនុស្ស មួយចំនួនតែប៉ុណ្ណោះ?

(៥) តើមានច្បាប់ណាខ្លះដែលលក្ខណៈប្រតិសកម្មក្នុងការអនុវត្តច្បាប់នោះ ឬទេ?

(៦) តើមន្ត្រីសាធារណៈ និងមន្ត្រីរដ្ឋាភិបាល ឋិតនៅក្រោមអំណាចនៃច្បាប់ ឬទេ?

- មើល**នីតិរដ្ឋ** តាមការពិនិត្យអំពី វត្តមាន ឬ អវត្តមាននៃលក្ខណៈវិនិច្ឆ័យជាក់លាក់ និង អាចកត់សម្គាល់បាន នៃច្បាប់ឬ ប្រព័ន្ធច្បាប់

- តើមានសំណួរអ្វីខ្លះទៀតដែលគួរលើកឡើង ដើម្បីដឹងថាមាននីតិរដ្ឋ ឬទេ?

# 7. អត្ថន័យនៃការផ្លាស់ប្តូរឥរិយាបថជាវិជ្ជមាន

- តើឥរិយាបថរបស់មនុស្សអាចផ្លាស់ប្តូរបាន ឬទេ?
- មានកត្តាអ្វីខ្លះដែលមានឥទ្ធិពលលើឥរិយាបថរបស់មនុស្ស?
- តើអ្វីហៅថា ការផ្លាស់ឥរិយាបថជាវិជ្ជមាន?

- ឥរិយាបថរបស់មនុស្ស អាចកែប្រែបាន (វិជ្ជមាន ឬ អវិជ្ជមាន)
- កត្តា ដូចជា ការឱ្យតម្លៃរបស់សង្គមចំពោះឥរិយាបទជាក់លាក់ វិធានច្បាប់ និងយន្តការសម្រាប់អនុវត្តវិធានទាំងឡាយ។
- មនុស្សលោកឱ្យតម្លៃខ្ពស់ចំពោះ សិទ្ធិសេរីភាពបុគ្គល សមធម៌ ភាពសមហេតុផល ភាពសមរម្យ និងយុត្តិធម៌សង្គម សិទ្ធិលើទ្រព្យសម្បត្តិឯកជន ភាពស្មើភាពគ្នាចំពោះមុខច្បាប់ និងលទ្ធិប្រជាធិបតេយ្យ ដើម្បីសុវត្ថិភាពសង្គម សុខសន្តិភាព ស្ថេរភាព និងចេរភាពនៃការអភិវឌ្ឍ
- ការយកខ្សែ លុយ អំណាច និងតួនាទីរដ្ឋបាល យោធា ឬ នយោបាយ ទៅធ្វើសកម្មភាពសាធារណៈដើម្បីប្រជាប្រិយភាពនយោបាយ គឺជាឥរិយាបថអវិជ្ជមាន ដែលសង្គមមិនគួរចូលរួមគាំទ្រ ឬ ឱ្យតម្លៃឡើយ
- អ្នកនយោបាយដែលមានតួនាទីក្នុងស្ថាប័នសាធារណៈ រួមទាំង អនុរដ្ឋលេខាធិការ រដ្ឋលេខាធិការ រដ្ឋមន្ត្រី នាយករដ្ឋមន្ត្រី មិនគួរនិយាយអំពីបក្សនយោបាយរបស់ខ្លួន ក្នុងពេលបំពេញមុខងារសាធារណៈ និងក្រៅអំឡុងពេលយុទ្ធនាការបោះឆ្នោត ឡើយ

- ឥរិយាបថជាវិជ្ជមាន គួរតែសំដៅដល់

1. ឥរិយាបទដែលគោរពសិទ្ធិអ្នកដ៏ទៃក្នុងការអនុវត្តនូវសិទ្ធិសេរីភាពរបស់ខ្លួន
2. ឥរិយាបទអហឹង្សា មិនរើសអើង និងមិនប្រមាថអាយុជីវិតរបស់ខ្លួន និងរបស់អ្នកដទៃ
3. ឥរិយាបទដែលស្រឡាញ់បរិស្ថានធម្មជាតិ
4. ឥរិយាបទដែលគោរពច្បាប់ជាជាងគោរពចំពោះបុគ្គលមានតួនាទីអំណាចបុណ្យស័ក្តទ្រព្យសម្បត្តិ
5. ឥរិយាបទដែលស្អាតស្អំ តម្លាភាព មិនលួចលាក់ មិនពុករលួយ
6. ឥរិយាបទនៃការទទួលខុសត្រូវចំពោះទង្វើរបស់មន្ត្រីសាធារណៈ និង
7. ឥរិយាបទនៃការស្គាល់យល់ដឹងគោរពការពារសិទ្ធិសេរីភាពមនុស្ស និងទ្រព្យសម្បត្តិឯកជន ដោយមន្ត្រីសាធារណៈ និងអ្នកនយោបាយដោយមិនគិតពីទស្សនៈឬនិន្នាការនយោបាយ

# 8. ការដោះស្រាយបណ្តឹងតវ៉ា-វិវាទក្រៅប្រព័ន្ធតុលាការ

- ដូចម្តេចហៅថា ការដោះស្រាយបណ្តឹងតវ៉ា-វិវាទក្រៅប្រព័ន្ធតុលាការ (ADR)?
- តើការដោះស្រាយបណ្តឹងតវ៉ា-វិវាទក្រៅប្រព័ន្ធតុលាការមានអ្វីខ្លះ?
- <u>ហេតុអ្វីគួរធ្វើការដោះស្រាយបណ្តឹងតវ៉ា-វិវាទក្រៅប្រព័ន្ធតុលាការ?</u>

# វិធីសាស្ត្រ និងគោលបំណង
# នៃការដោះស្រាយបណ្តឹងតវ៉ា-វិវាទ
# ក្រៅប្រព័ន្ធតុលាការ (ADR)

ដូចម្តេចហៅថា ការដោះស្រាយបណ្តឹងតវ៉ា-វិវាទក្រៅប្រព័ន្ធតុលាការ(ADR)?

តើការដោះស្រាយបណ្តឹងតវ៉ា-វិវាទក្រៅប្រព័ន្ធតុលាការ មានអ្វីខ្លះ?

ហេតុអ្វីគួរធ្វើការដោះស្រាយបណ្តឹងតវ៉ា-វិវាទក្រៅប្រព័ន្ធតុលាការ?

## ដូចម្ដេចហៅថា ការដោះស្រាយបណ្ដឹងតវ៉ា-វិវាទក្រៅប្រព័ន្ធតុលាការ(ADR)? ចូរពិភាក្សា ឬ បង្ហាញពីការយល់ដឹង

# វិធីសាស្ត្រនៃការដោះស្រាយបណ្តឹងតវ៉ា-វិវាទក្រៅប្រព័ន្ធតុលាការ

- ការពិភាក្សាអំពីបណ្តឹងតវ៉ា និងដំណោះស្រាយ
- ការវិនិច្ឆ័យផ្នែករដ្ឋបាលលើករណីបណ្តឹងតវ៉ា
- ការចរចារកដំណោះស្រាយចំពោះបណ្តឹងតវ៉ា-វិវាទ
- ការផ្សះផ្សាសម្រុះសម្រួលបណ្តឹងតវ៉ា-វិវាទ
- ការវិនិច្ឆ័យរបស់អ្នកជំនាញមិនចងកាតព្វកិច្ចអនុវត្ត
- ការធ្វើអាជ្ញាកណ្តាល ឬ មជ្ឈត្តការលើករណីវិវាទ








ការមិនឯកភាពគ្នា ឬ វិវាទកើតឡើង

រកការដោះស្រាយបណ្តឹងតវ៉ា ឬ វិវាទក្រៅប្រព័ន្ធតុលាការ












**ការចរចារផ្អែកលើផលប្រយោជន៍** ទទួលលទ្ធផល ឈ្នះ-ឈ្នះ ទាំងសងខាង

រីឯការចរចារផ្អែកលើ**ជំហរ ឬ អំណាច** ទទួលលទ្ធផល ឈ្នះ-ចាញ់ ឬ ចាញ់ទាំងសងខាង

គ្មានការចរចារ  ឬ ខ្វះគោលការណ៍សម្រាប់ចរចារ ឬ ចរចារមិនបានសម្រេច នាំឱ្យការតវ៉ា ឬ ការមិនពេញចិត្ត នៅតែមាន ហើយអាចក្លាយជាភ្លើងកំហឹង ឬ កម្លាំងរិះគន់ដល់រាជរដ្ឋាភិបាល







**យន្តការទទួលបណ្តឹងតវ៉ា និងសម្រុះសម្រួល ÷** នៅចំពោះមុខ**អ្នកសម្រុះសម្រួល** ដែលអព្យាក្រឹត្យ គ្មានទំនាស់ផលប្រយោជន៍ និងផ្តល់ការគោរពចំពោះគូភាគីដូចគ្នា (អ្នកសម្រុះសម្រួល ត្រូវខិតខំបង្ហាញឱ្យឃើញថា ខ្លួនមិនឈរនៅខាងភាគីណាមួយឡើយ  មិនស្តីបន្ទោសដល់ភាគីណាមួយ ហើយបង្កឱកាសឱ្យភាគីនិយាយគ្នាតាមសម្រួលម្នាក់ម្តង និងស្តាប់គ្នានិយាយយ៉ាងយកចិត្តទុកដាក់) នាំឱ្យវិវាទ ឬ ការតវ៉ានោះ អាចដោះស្រាយបានតាមការឯកភាពព្រមព្រៀង ឬ ការយល់ដឹងរបស់គូភាគី។

## ចំណុចដែល អ្នកសម្រុះសម្រួល គួរពិនិត្យពិចារណា

- តើចំណុចទាមទារក្នុងពាក្យបណ្តឹង មានអ្វីខ្លះ?
- តើជាបណ្តឹងបុគ្គល (ពាក់ព័ន្ធបុគ្គលម្នួយៗ) ឬ បណ្តឹងជារួម (ពាក់ព័ន្ធបុគ្គលច្រើនក្នុងបណ្តឹងតែមួយ)?
- តើត្រូវរៀបចំធ្វើការសម្រុះសម្រួលបែបណាក្នុងករណីវិវាទរួម? ករណីមានវិវាទបុគ្គល និងវិវាទរួម ក្នុងពាក្យបណ្តឹងតែមួយ?
- តើមានបញ្ហាអង្គហេតុ ដែលត្រូវចុះពិនិត្យរួមគ្នាឬទេ?
- ក្រោយការសម្រុះសម្រួល តើចំណុចទាមទារណាខ្លះដែលគូភាគីបានឯកភាពអំពីដំណោះស្រាយ ឬ ម្ចាស់បណ្តឹងសុខចិត្តដកការទាមទារ? ចំណុចទាមទារណាខ្លះដែលមិនឯកភាពគ្នា?
- តើគួរដោះស្រាយបែបណាចំពោះចំណុចទាមទារតវ៉ា ដែលគ្មានការឯកភាពគ្នានោះ?
- ធ្វើរបាយការណ៍ ឬ កំណត់ហេតុនៃការផ្សះផ្សារសម្រុះសម្រួលឱ្យបានច្បាស់លាស់ និងឆ្លុះបញ្ចាំងលទ្ធផលពិភាក្សា និងការលើកឡើងជាដំណោះស្រាយរបស់គូភាគី

**យន្តការដោះស្រាយបណ្តឹងតវ៉ា (អាជ្ញាកណ្តាល)** ÷ ក្រោយការសម្រុះសម្រួល បើមានចំណុចវិវាទ ឬ ចំណុចទាមទារតវ៉ា មិនទាន់ឯកភាពគ្នា ឬ មិនអាចដោះស្រាយតាមការចរចារគ្នា អាចសម្រុះសម្រួលមួយថ្នាក់ទៀត ឬ និង **សម្រេចសេចក្តី**ចំពោះការទាមទារតវ៉ានោះ។






តំណាងគណៈកម្មការ (អាជ្ញាកណ្តាល) ត្រូវស្តាប់ និងកត់ត្រាការអះអាងរបស់គូភាគីពិនិត្យអង្គហេតុ ភស្តុតាង ស្តាប់សាក្សី និង បកស្រាយច្បាប់ ឬ គោលនយោបាយពាក់ព័ន្ធមុននឹងចេញសេចក្តីសម្រេចចំពោះចំណុចទាមទារតវ៉ានោះ ដោយផ្តល់ហេតុផលផង។

# គោលបំណងនៃការដោះស្រាយបណ្តឹងតវ៉ា-វិធានក្រៅប្រព័ន្ធតុលាការ

- ការរក្សាភាពឯកជន ឬ ការសម្ងាត់របស់ភាគី?
- ស្វ័យតភាពរបស់ភាគី?
- នីតិវិធីទន់ភ្លន់ និងឆាប់រហ័ស?
- លទ្ធភាពជ្រើសរើសអ្នកដោះស្រាយដែលមានសមត្ថភាព ជំនាញ ឥតលំអៀង និងគ្មានទំនាស់ផលប្រយោជន៍?
- ការកំណត់ដែនសមត្ថកិច្ចរបស់អ្នកដោះស្រាយ?
- ប្រសិទ្ធិភាព និងដែនកំណត់នៃការអនុវត្តនូវដំណោះស្រាយ?
- ការចំណាយថវិការលើដំណើការដោះស្រាយ?

# ដំណាក់កាលទាររបស់អាជ្ញាកណ្តាល

- គូភាគីមាន ឬ ធ្វើកិច្ចព្រមព្រៀងស្តីពីមជ្ឈត្តការ
- ការដាក់ពាក្យបណ្តឹងតវ៉ាជូនមជ្ឈត្តករ ឬ ការជូនដំណឹងអំពីមជ្ឈត្តការ
- ការជ្រើសរើសតែងតាំងមជ្ឈត្តការ និងការប្រកាសអំពីទំនាស់ផលប្រយោជន៍
- ការពិនិត្យសំណុំរឿង
- ការប្រជុំត្រៀមមុនសវនាការ ដើម្បីកំណត់ចំណុចវិវាទ និងនីតិវិធីលម្អិត
- អាចមានការប្រជុំផ្សះផ្សាសម្រុះសម្រួលមុនសវនាការ បើគូភាគីយល់ព្រមធ្វើ

# ដំណាក់កាលនៃការបើកកាតអាជ្ញាកណ្តាល

- ការធ្វើសវនាការផ្ទាល់មាត់លើចំណុចវិវាទដែលមិនសះជាគ្នា (ឬ សវនាការតែលើឯកសារដែលភាគីដាក់ជូន)
- ភាគីវិវាទ ឬអ្នកតំណាងរបស់គូភាគី ចូលរួមសវនាការដើម្បីអះអាង ឬ និងដោះសារ
- អាជ្ញាកណ្តាល ស្តាប់ការបង្ហាញអង្គហេតុ និងពិនិត្យភស្តុតាងដែលភាគីដាក់ជូន
- ការពិនិត្យរាល់ឯកសារ និងភស្តុតាង ដែលភាគីមួយបញ្ជូនមកអាជ្ញាកណ្តាល ហើយបញ្ជូនទៅភាគីម្ខាងទៀត ដែលភាគីនិមួយៗមានសិទ្ធិជំទាស់ចំពោះឯកសារ និងភស្តុតាងទាំងឡាយ
- ការសរសេរ ត្រួតពិនិត្យខ្លឹមសារ ហេតុផល និងមូលដ្ឋាននៃសេចក្តីបង្គាប់ និងចេញសេចក្តីបង្គាប់តាមពេលវេលាកំណត់ ឬ ដែលគូភាគីបានឯកភាពគ្នា។

# លក្ខណៈសម្បត្តិរបស់អាជ្ញាកណ្តាល ឬ មជ្ឈត្តករ

- ត្រូវមានឯករាជ្យ  ភាពឥតលម្អៀង មានប្រសិទ្ធភាព  និងតម្លាភាព
- មិនត្រូវឋិតក្នុងស្ថានភាពមានទំនាស់ផលប្រយោជន៍
- មិនត្រូវបំពានអំណាចសមត្ថកិច្ចរបស់ខ្លួន
- ត្រូវគោរពតាមការព្រមព្រៀងរបស់គូភាគី
- ត្រូវប្រកាន់នូវគោលការណ៍យុត្តិធមិធម្មជាតិ
- ត្រូវគោរពគោលការណ៍ស្វ័យតភាពរបស់គូភាគី
- របាយការណ៍ស្តីពីដំណោះស្រាយត្រូវមានភាពត្រឹមត្រូវច្បាស់លាស់
- រាល់សេចក្តីសម្រេច ឬ សេចក្តីបង្គាប់ត្រូវមានហេតុផលច្បាស់លាស់ និងសមរម្យ

# ការអនុវត្តន៍សេចក្ដីបង្គាប់អាជ្ញាកណ្ដាល ដោយតុលាការ

- ប្រសិនបើភាគីណាមួយ មិនអនុវត្តសេចក្ដីបង្គាប់ចងកាតព្វកិច្ច ភាគីម្ខាងទៀត អាចស្នើសុំទៅតុលាការ ឱ្យទទួលស្គាល់ និងបង្ខំឱ្យអនុវត្តសេចក្ដីបង្គាប់នោះ
- ក្របខ័ណ្ឌច្បាប់៖
  – ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦ (ល័ក្ខខ័ណ្ឌនៃការអនុវត្តដោយបង្ខំ)
  – អនុសញ្ញាទីក្រុងញូយក ស្ដីពីការទទួលស្គាល់ និងការអនុវត្តមជ្ឈត្តវិនិច្ឆ័យបរទេស

- ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦ (ល័ក្ខខ័ណ្ឌនៃការអនុវត្តដោយបង្ខំ)

**មាត្រា ៣៥០ ចែងថា÷**

(១) ការអនុវត្តដោយបង្ខំ ត្រូវធ្វើឡើងដោយផ្អែកលើលិខិតអនុវត្ត។

(២) លិខិតអនុវត្ត គឺជាលិខិតដែលបានកំណត់ដូចខាងក្រោមនេះ ÷

(ជ) សេចក្ដីសម្រេចមជ្ឈត្តករដែលមានដីកាសម្រេចអនុវត្តដែលបានចូលជាស្ថាពរ តាមបញ្ញត្តិនៃមាត្រា៣៥៣(ដីកាសម្រេចអនុវត្តសេចក្ដីសម្រេចមជ្ឈត្តករ)នៃក្រមនេះ

(ឈ) កំណត់ហេតុដែលបានកំណត់ក្នុងមាត្រា ២២២ (អានុភាពនៃកំណត់ហេតុស្ដីពីការសះជា ជាអាទិ៍ ដែលចែងថា ក្នុងករណីមានការសះជា ការលះបង់នូវការទាមទារ ឬ ការទទួលស្គាល់នូវការទាមទារ ត្រូវបានកត់ត្រាក្នុងកំណត់ហេតុ កំណត់ត្រានេះ មានអានុភាពដូចគ្នានឹងសាលក្រមស្ថាពរ) នៃក្រមនេះ និងកំណត់ហេតុផ្សេងៗទៀតដែលមានអានុភាពដូចសាលក្រម ឬ សាលដីកាដែលបានចូលជាស្ថាពរ។

• ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦ (ល័ក្ខខ័ណ្ឌនៃការអនុវត្តដោយបង្ខំ)

**មាត្រា ៣៥៣** ចែងថា÷

(១) ដើម្បីធ្វើការអនុវត្តដោយបង្ខំ ដោយផ្អែកលើសេចក្តីសម្រេចរបស់មជ្ឈត្តករ ទោះបីជាសេចក្តីសម្រេចមជ្ឈត្តករក្នុងប្រទេសក៏ដោយ សេចក្តីសម្រេចមជ្ឈត្តករបរទេសក៏ដោយ ត្រូវទទួលដីកាសម្រេចអនុវត្តរបស់តុលាការនៅព្រះរាជាណាចក្រកម្ពុជា។

(២) ភាគីដែលដាក់ពាក្យសុំឱ្យតុលាការចេញដីកាសម្រេចអនុវត្តសេចក្តីសម្រេចមជ្ឈត្តករ ត្រូវដាក់លិខិតដូចខាងក្រោមនេះ÷

(ក) ច្បាប់ដើមនៃសេចក្តីសម្រេចមជ្ឈត្តករដែលត្រូវបានបញ្ជាក់ថាត្រឹមត្រូវ ឬ ឯកសារចម្លងដែលមានសេចក្តីបញ្ជាក់ថាត្រឹមត្រូវ។

(ខ) ច្បាប់ដើមនៃកិច្ចសន្យាមជ្ឈត្តកម្ម ឬ ឯកសារចម្លងនៃកិច្ចសន្យានេះ ដែលមានសេចក្តីបញ្ជាក់ត្រឹមត្រូវ។

• ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦ (ល័ក្ខខ័ណ្ឌនៃការអនុវត្តដោយបង្ខំ)

**មាត្រា ៣៥៣** ចែងថា÷

(៣) តុលាការអាចបដិសេធការអនុវត្តសេចក្ដីសម្រេចមជ្ឈត្តករបាន បើភាគីដែលនឹងទទួលរងការខូចខាតផលប្រយោជន៍ពីការអនុវត្តសេចក្ដីសម្រេចមជ្ឈត្តករ សំអាងបញ្ជាក់អំពីហេតុដូចខាងក្រោមនេះ÷

(ក) ភាគីនៃកិច្ចសន្យាមជ្ឈត្តកម្ម គ្មានសមត្ថភាព ឬ កិច្ចសន្យាមជ្ឈត្តកម្មនោះត្រូវចាត់ទុកជាមោឃៈ តាមបទដ្ឋានគតិយុត្តដែលគូភាគីបានកំណត់ជាច្បាប់យោង ឬ បទដ្ឋានគតិយុត្តនៃប្រទេសដែលសេចក្ដីសម្រេចមជ្ឈត្តករត្រូវបានធ្វើឡើង ប្រសិនបើគ្មានការកំណត់ដោយគូភាគី។

(ខ) ភាគីដែលនឹងទទួលរងនូវការខូចខាតផលប្រយោជន៍ពីការអនុវត្តសេចក្ដីសម្រេចមជ្ឈត្តករ មិនបានទទួលសេចក្ដីជូនដំណឹងសមរម្យ អំពីការជ្រើសតាំងមជ្ឈត្តករ ឬ នីតិវិធីមជ្ឈត្តកម្ម ឬ មិនអាចការពារខ្លួនដោយសារមូលហេតុផ្សេងទៀត។

• ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦ (ល័ក្ខខ័ណ្ឌនៃការអនុវត្តដោយបង្ខំ)

**មាត្រា ៣៥៣** ចែងថា៖

(៣) (គ) សេចក្តីសម្រេចមជ្ឈត្តករ ទាក់ទងនឹងវិវាទដែលមិនបានកំណត់នៅក្នុងចំណុចដែលត្រូវទទួលមជ្ឈត្តកម្ម ឬវិវាទក្រៅទំហំនៃចំណុចនោះ ឬមានសេចក្តីសម្រេចអំពីចំណុចដែលហួសពីទំហំនៃចំណុចដែលត្រូវទទួលមជ្ឈត្តកម្ម ។

(ឃ) ការរៀបចំអង្គភាពវិនិច្ឆ័យនៃមជ្ឈត្តកម្ម ឬ នីតិវិធីនៃមជ្ឈត្តកម្ម មិនស្របតាមការព្រមព្រៀងរបស់ គូភាគី ឬ បើគ្មានការព្រមព្រៀងនោះទេ មិនស្របតាមបទដ្ឋានគតិយុត្តនៃប្រទេសដែលមជ្ឈត្តកម្មត្រូវបានធ្វើឡើង។

(ង) សេចក្តីសម្រេចមជ្ឈត្តករ មិនទាន់មានអានុភាពចងភាគី ឬ ត្រូវបានលុបចោលដោយតុលាការនៃប្រទេសដែលសេចក្តីសម្រេចមជ្ឈត្តករនោះត្រូវបានធ្វើឡើង ឬ ប្រទេសដែលមានបទដ្ឋានគតិយុត្តដែលជាមូលដ្ឋាននៃសេចក្តីសម្រេចមជ្ឈត្តករនោះ។

- ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦ (ល័ក្ខខ័ណ្ឌនៃការអនុវត្តដោយបង្ខំ)

**មាត្រា ៣៩៣** ចែងថា÷

(៤) តុលាការអាចបដិសេធការអនុវត្តសេចក្ដីសម្រេចមជ្ឍត្តករ ប្រសិនបើយល់ឃើញថាមានហេតុដូចខាងក្រោមនេះ

(ក) ចំណុចដែលជាកម្មវត្ថុនៃវិវាទ មិនអាចដោះស្រាយបានដោយមជ្ឍត្តកម្ម។

(ខ) ការទទួលស្គាល់ ឬការអនុវត្តសេចក្ដីសម្រេចមជ្ឍត្តករ ផ្ទុយនឹងសណ្ដាប់ធ្នាប់សាធារណៈ

(៧) ការចេញដីកាសម្រេចអនុវត្ត ត្រូវធ្វើឡើងដោយមិនស្រាវជ្រាវអំពីភាពត្រឹមត្រូវ ឬ មិនត្រឹមត្រូវនៃសេចក្ដីសម្រេចមជ្ឍត្តករ លើកលែងតែករណីដែលកំណត់ក្នុងកថាខណ្ឌទី ៣ និងកថាខណ្ឌទី ៤ ខាងលើនេះ។

# កត្តាគួរយកចិត្តទុកដាក់ក្នុងការតាក់តែង ឬ និងដំណើការនូវយន្តការដោះស្រាយបណ្តឹងតវ៉ា-វិវាទក្រៅប្រព័ន្ធតុលាការ

គួរមានការយកចិត្តទុកដាក់លើចំណុចដូចខាងក្រោមក្នុងការតាក់តែង និងដំណើការនូវយន្តការដោះស្រាយបណ្តឹងតវ៉ាវិវាទក្រៅប្រព័ន្ធតុលាការ

- ការរក្សាភាពឯកជន ឬ ការសម្ងាត់របស់ភាគី (ភាពអសាធារណៈនៃដំណើការដោះស្រាយ និងត្រូវមានការយកចិត្តទុកដាក់អំពីការផ្សព្វផ្សាយរបាយការណ៍ស្តីពីការដោះស្រាយ សេចក្តីសម្រេច និងសេចក្តីបង្គាប់)
- ស្វ័យតភាពរបស់ភាគី (ជម្រើស និងការព្រមព្រៀងរបស់គូភាគី)
- ភាពទន់ភ្លន់ និងឆាប់រហ័សនៃនីតិវិធី និងដំណើការដោះស្រាយ
- លទ្ធភាពជ្រើសរើសអ្នកដោះស្រាយដែលមានសមត្ថភាព ជំនាញ ឥតលំអៀង និងគ្មានទំនាស់ផលប្រយោជន៍
- ការកំណត់ដែនសមត្ថកិច្ចរបស់អ្នកដោះស្រាយ
- ប្រសិទ្ធិភាព និងដែនកំណត់នៃការអនុវត្តនូវដំណោះស្រាយ
- ការចំណាយថវិការលើដំណើការដោះស្រាយ។

# គោលការណ៍ និងតម្រូវការនៃការតាក់តែងពិនិត្យច្បាប់សម្រាប់អភិបាលកិច្ចល្អ និងការផ្លាស់ប្តូរសេរីយាបននជាវិជ្ជមាន

**9. បទប្បញ្ញត្តិរដ្ឋធម្មនុញ្ញទាក់ទងនឹង គោលការណ៍ និងដំណើការនៃការធ្វើច្បាប់**

ត្រូវមានការយល់ដឹងអំពីលក្ខខណ្ឌតម្រូវក្នុងរដ្ឋធម្មនុញ្ញ ដែលច្បាប់ជាតិ និង លិខិតបទដ្ឋានគតិយុត្តត្រូវអនុលោមតាម

- អំពីគោលការណ៍គន្លឹះៗដែលជាមគ្គុទេសក៏សម្រាប់អ្នកធ្វើច្បាប់ និង អ្នកតាក់តែងច្បាប់
- អំពីដំណើការធ្វើច្បាប់

# អំពីគោលការណ៍គន្លឹះៗ ក្នុងរដ្ឋធម្មនុញ្ញ

ចូរអាន និងវិភាគនូវបទប្បញ្ញត្តិនៃរដ្ឋធម្មនុញ្ញ ម្តងមួយៗ។ តើអ្នកចង់វិភាគលើគោលការណ៍ ឬ បទប្បញ្ញត្តិណាមួយដែលពាក់ព័ន្ធនឹងការងាររបស់អ្នក ឬទេ?

- មាត្រា ៣១ ដល់ មាត្រា ៥០
- មាត្រា ៥៨
- មាត្រា ៦០
- មាត្រា ៦២
- មាត្រា ៦៣
- មាត្រា ៦៦
- មាត្រា ១២៨ ថ្មី
- មាត្រា ១៣០ ថ្មី

# អំពីដំណើការធ្វើច្បាប់ក្នុងរដ្ឋធម្មនុញ្ញ

ចូរអាន និងវិភាគបទប្បញ្ញត្តិនៃរដ្ឋធម្មនុញ្ញ ម្តងមួយៗ។

- មាត្រា ៩១ ថ្មី
- មាត្រា ៩២
- មាត្រា ៩៣ ថ្មី
- មាត្រា ១១៣ ថ្មី
- មាត្រា ១៣៦ ថ្មី
- មាត្រា ១៤០ ថ្មី
- មាត្រា ១៤១ ថ្មី

# 10. គោលបំណង កត្តាប្រឈម វិធីសាស្ត្រ និងទិចនិកនៃការតាក់តែងច្បាប់

## គោលបំណងនានានៃការធ្វើវិធានច្បាប់

- ដើម្បីគ្រប់គ្រង រិតត្បិត ឬ អភិរក្ស vs. បង្កបរិយាកាស ឬ ផ្តល់សេរីភាព ឬ ធ្វើសេរីភាវូនីកម្ម
- តាមការចែង/by stipulation vs. តាមទំនាញហេតុ/by implication vs. តាមការខកខានឥតបានកំណត់ដោយភាគី/by default

- សម្រាប់ល្អមើល (មាននៅលើក្រដាស) vs. សម្រាប់មានអារម្មណ៍ល្អ (មានក្នុងតថភាព)
- សម្រាប់បំពេញចិត្តមហាអំណាចបរទេស ឬ អ្នកផ្តល់ជំនួយ vs. សម្រាប់បំពេញចិត្តប្រជាពលរដ្ឋដែលជាម្ចាស់ឆ្នោត
- សម្រាប់ប្រយោជន៍សាធារណៈ vs. សម្រាប់បម្រើផលប្រយោជន៍របស់អ្នកនយោបាយ គណបក្សនយោបាយ ឬ មន្ត្រីការិយាល័យធិបតេយ្យ។

# សំណួរ

តាមការកត់សម្គាល់របស់អ្នក

តើអាចនិយាយថាគោលបំណង ឬ ចេតនានៃការធ្វើវិធានច្បាប់ជាទូទៅនៅកម្ពុជានាពេលបច្ចុប្បន្ន មានចរិកលក្ខណៈបែបណាដែរ?

# កត្តាប្រឈមក្នុងការធ្វើវិធានច្បាប់

- ការធ្វើវិធានច្បាប់ មិនមែនជាការងារសាមញ្ញ ឬគ្រាន់តែជាដំណើការចម្លង និងកាត់តពីគេនោះទេ

- ដូច្នេះ ភាពប្រឈម បណ្ដាលមកពីអ្វីខ្លះ?

# ហេតុផលនៃភាពប្រឈមនេះអាចមានដូចជា

- មានក្រុមផលប្រយោជន៍ និងអ្នកតស៊ូមតិច្រើនក្រុម (interest and lobbyist groups) ហើយនិងក្រុមស្វែងរកឱកាសអំពីទាញយកប្រយោជន៍ និងចាំទទួលយកប្រយោជន៍ទទេរៗ (rent seekers and free-rider groups)

- ចំណោទបញ្ហាអំពីនីតិសាធារណៈ និងជម្រើសសាធារណៈ
(Public law and public choices question)
  - តើពិតជាមានសម្លេងភាគច្រើនរបស់អ្នកធ្វើច្បាប់ មែនឬទេ?
  - តើមានលក្ខណៈវិនិច្ឆ័យបែបណាសម្រាប់កំណត់សម្លេងភាគច្រើនដែលមានន័យខ្លឹមសារពិតប្រាកដ?
  - តើវាពិតជាត្រូវបានធ្វើឡើងដើម្បីផលប្រយោជន៍សាធារណៈ ឬផលប្រយោជន៍ទូទៅ មែនឬ?

នៅពេលមានការផ្លាស់ប្តូរអ្នកនយោបាយ ជាញឹកញាប់ក៏មានការកែប្រែច្បាប់ក្រោយពេលផ្លាស់ប្តូរអ្នកនយោបាយផងដែរ។

- កង្វះការស្រាវជ្រាវអំពីគោលនយោបាយ ជាក់លាក់ និងគ្រប់គ្រាន់ ព្រមទាំងខ្វះទិន្នន័យតឹកតាងសម្រាប់គាំទ្រដល់ការជ្រើសរើស ឬ ការតាក់តែងវិធានច្បាប់ជាក់លាក់។

# អ្វីដែលត្រូវមានជាមុន

- ចំណេះដឹងអំពីប្រធានបទផ្នែកគោលនយោបាយ ឬ ច្បាប់សម្រាប់មានសមត្ថភាពផ្តល់យោបល់លើសេចក្តីព្រាងអត្តបទច្បាប់ (តាមការអានសៀវភៅសិក្សា/ព្រឹត្តិបត្រ/បោះពុម្ពផ្សាយ/របាយការណ៍សិក្សាស្រាវជ្រាវ/ការសិក្សាពីករណីជាក់ស្តែងស្តីពីកម្មវត្ថុពាក់ព័ន្ធ)
- ចេះប៉ាន់ប្រមាណពីផលប៉ះពាល់ដែលអាចកើតមាននៃលិខិតូបករណ៍គតិយុត្ត ឬ របាយការណ៍ស្តីពីការប៉ាន់ប្រមាណពីផលប៉ះពាល់ដែលអាចកើតមាន
- យល់ឋានានុក្រមនៃច្បាប់ និងទំនាស់នៃច្បាប់។

# វិធីសាស្ត្រក្នុងការតាក់តែងច្បាប់

- មិនអាចជៀសវាងនូវការធ្វើច្បាប់ ឬ វិធានច្បាប់សម្រាប់គ្រប់គ្រងសង្គមបានទេ
- មានវិធីសាស្ត្រត្រឹមត្រូវក្នុងការតាក់តែងច្បាប់ យើងអាចឆ្លើយតបចំពោះសំណួរជាច្រើនបាន
- ដូច្នេះតើវិធីសាស្ត្រអ្វីខ្លះក្នុងការតាក់តែងច្បាប់ដែលអ្នកបានដឹង ឬ ធ្លាប់ប្រើប្រាស់កន្លងមក?

1. វិធីសាស្ត្រពហុនិយម (Pluralism)
2. វិធីព្រហ្មទណ្ឌ (Criminalization)
3. វិធីសាស្ត្រចម្លងតាមច្បាប់របស់ប្រទេសផ្សេងទៀត
4. វិធីសាស្ត្រធ្វើតាមក្តីប្រាថ្នារបស់រដ្ឋមន្ត្រី ឬ អ្នកដឹកនាំនយោបាយ ឬ តាមគំនិតរបស់មន្ត្រី ការិយាល័យធិបតេយ្យ
5. វិធីសាស្ត្រតាក់តែងច្បាប់**ត្រេនស៊ីទីវ** (transitive) vs. **អីនត្រេនស៊ីទីវ**( intransitive)
6. វិធីសាស្ត្រតាក់តែងច្បាប់ឈរលើទស្សនទានរបស់ថៅក្រម
7. វិធីសាស្ត្រតាក់តែងច្បាប់ផ្អែកលើអភិបាលកិច្ចល្អ
8. វិធីសាស្ត្រតាក់តែងច្បាប់ផ្អែកលើហេតុពិត និងឡូស៊ិក (Facts and Logic)។

- ហេតុអ្វីបានជាអ្នកតាក់តែងច្បាប់ជ្រើសរើសប្រើវិធីសាស្ត្របីតំបូងគេ? វាជាអាចថិកំបាំងរបស់អ្នកតាក់តែងច្បាប់ ដោយសារគ្មានវិធីសាស្ត្រផ្សេងទៀត ឬដោយសារស្ថាប័នធ្វើច្បាប់?
- ចុះចំណែកឯវិធីសាស្ត្រទី៤ និងទី៥វិញ យ៉ាងណាដែរ?

# វិធីសាស្ត្រដែលត្រូវបានលើកទឹកចិត្តឱ្យប្រើ

- វិធីសាស្ត្រទី៦ ទី៧ និង ទី៨ ប្រសិនបើចង់ឃើញ និងចង់ទទួលបានផលពីការផ្លាស់ប្តូរជាវិជ្ជមានផ្នែកសង្គម និងនយោបាយ នៅកម្ពុជាក្នុងពេលប៉ុន្មានឆ្នាំខាងមុខ

# ការតាក់តែងច្បាប់បែបទ្រេនស៊ីទីវ vs. អីនទ្រេនស៊ីទីវ

## ច្បាប់បែបទ្រេនស៊ីទីវ (Transitive law):

គឺជាប្រភេទច្បាប់ដែលសេចក្ដីលម្អិតភាគច្រើនមានចែងក្នុងអត្ថបទច្បាប់នោះតែម្ដង។

## ច្បាប់បែបអីនទ្រេនស៊ីទីវ (Intransitive law):

គឺជាប្រភេទច្បាប់ដែលចែងសេចក្តីលម្អិតតិចតួច ឬ គ្មានសេចក្តីលម្អិតទេ ហើយទុកឱ្យចែងសេចក្តីលម្អិតក្នុងលិខិតបទដ្ឋានគតិយុត្តសម្រាប់អនុវត្តច្បាប់នោះដែលចេញដោយអង្គប្រតិបត្តិ។ វាផ្តល់សិទ្ធិអំណាចឱ្យទីភ្នាក់ងារ ឬ ក្រសួងទទួលបន្ទុកអនុវត្តច្បាប់ ជាអ្នករៀបចំនូវបទប្បញ្ញត្តិលម្អិតក្នុងទម្រង់ជាលិខិតបទដ្ឋានគតិយុត្ត។ វាអាចចោទជាសំណួរអំពីការចុះទន់ខ្សោយនៃអំណាចប្រជាធិបតេយ្យ។

- **ច្បាប់បែបអីនទ្រេនស៊ីទីវ** កំណត់តែគោលបំណង គោលការណ៍ទូទៅ លក្ខណៈវិនិច្ឆ័យគោល និង ការរៀបចំផ្នែកស្ថាប័ន ហើយទុកសេចក្តីលម្អិត ចែងក្នុងលិខិតបទដ្ឋានគតិយុត្ត។

- តើមានហេតុផលអ្វីខ្លះសម្រាប់ធ្វើច្បាប់បែបអីនទ្រេនស៊ីទីវ ហើយមិនធ្វើច្បាប់បែបទ្រេនស៊ីទីវ?

# ហេតុផលសម្រាប់ការធ្វើច្បាប់បែបអីនទ្រេនស៊ីទីវ

(1) សេចក្តីព្រាងច្បាប់មានបំណងដោះស្រាយនូវបញ្ហាសង្គមដ៏លំបាក និងសាំញ៉ាំ ដែលទាមទារឱ្យទីភ្នាក់ងារមួយចំនួនមានសិទ្ធិអំណាចពិសោធន៍ដោះស្រាយដោយប្រើដំណោះស្រាយផ្សេងៗគ្នា។

ការផ្តល់សិទ្ធិអំណាចឱ្យទីភ្នាក់ងារចេញ និងកែសម្រួល នូវវិធានលម្អិតដែលទំនងជាអាចដោះស្រាយបញ្ហានោះបាន មានន័យថា ផ្តល់សិទ្ធិអំណាចឱ្យទីភ្នាក់ងារនោះធ្វើការដកពិសោធន៍។

(២) ច្បាប់ដែលដោះស្រាយបញ្ហាសង្គមតែមួយចំណុច ប៉ុន្តែ មានក្រុមគោលដៅ ឬ អ្នកកាន់តួនាទីផ្សេងៗគ្នាជាច្រើន និងមានឥរិយាបទដែលបង្កបញ្ហាច្រើនបែប ហើយអ្នកតាក់តែងច្បាប់ គ្មានពេលធ្វើការស្រាវជ្រាវចាំបាច់ដើម្បីជួយដល់ការសរសេរនូវវិធានលម្អិតដែលត្រូវការសម្រាប់អនុវត្តច្បាប់នោះទេ។

- ច្បាប់ដែលដោះស្រាយបញ្ហាសង្គមតែមួយចំណុចដែលមានទម្រង់ខុសគ្នានៅទីកន្លែងផ្សេងគ្នានៃប្រទេស ហើយមានក្រុមគោលដៅ ឬ អ្នកកាន់តួនាទីផ្សេងៗគ្នា ជាមួយនឹងហេតុផលផ្សេងគ្នាសម្រាប់ឥរិយាបទរបស់ពួកគេនីមួយៗ ដូច្នេះអ្នកតាក់តែងច្បាប់មិនអាចសរសេរនូវវិធានលម្អិតសម្រាប់អនុវត្តលើតំបន់ផ្សេងៗគ្នានៃប្រទេស ឬ លើក្រុមគោលដៅ ឬ អ្នកកាន់តួនាទីខុសៗគ្នាបានទេ។

- ច្បាប់ដែលដោះស្រាយបញ្ហាសង្គមតែមួយចំណុច ឋិតក្នុងស្ថានភាពមានការប្រែប្រួលយ៉ាងឆាប់រហ័ស ដែលធ្វើឱ្យច្បាប់សរសេរថ្ងៃនេះ ក្លាយជាហួសសម័យប្រើប្រាស់នៅថ្ងៃស្អែក។

# ការតាក់តែងច្បាប់ឈរលើទស្សនទានរបស់ចៅក្រម

- ជាអភិក្រមនៃតាក់តែងច្បាប់មួយបែប ដែលផ្តោតការយកចិត្តទុកដាក់លើ
  - ឯកភាពនៃទម្រង់ និងគតិច្បាប់
  - ឃ្លាប្រយោគច្បាប់ និង
  - ពាក្យពេចន៍ដែលប្រើក្នុងអត្ថបទច្បាប់។ ការធ្វើបែបនេះនឹងផ្តល់នូវវិធានច្បាប់ដែលច្បាស់លាស់ និងគ្រប់គ្រាន់សម្រាប់ដោះស្រាយឆ្លើយតបនឹងសំណួរជាច្រើនដែលចោទឡើងក្នុងស្ថានភាពវិវាទផ្សេងៗគ្នា។

# ការតាក់តែងច្បាប់ឈរលើគោលការណ៍អភិបាលកិច្ចល្អ

វិធានការអភិបាលកិច្ច ជាវិធានការដែល

- ជួយកាត់បន្ថយនូវឱកាសរបស់មន្ត្រីក្នុងការប្រព្រឹត្តតាមទំនើងចិត្តយ៉ាងអនាធិតេយ្យ និងពុករលួយ
- ធានានូវគណនេយ្យភាព តម្លាភាព ការចូលរួម និងការធ្វើសេចក្តីសម្រេចផ្អែកលើវិធានច្បាប់ក្នុងដំណើរការធ្វើសេចក្តីសម្រេចរបស់រដ្ឋាភិបាល
- រៀបចំតាក់តែងច្បាប់ដើម្បីប្រឆាំងយ៉ាងស្វិតស្វាញទល់នឹងអំពើពុករលួយ។

- កម្រិតនូវឆន្ទានុសិទ្ធិដែលគ្មានគណនេយ្យភាពឱ្យនៅត្រឹមចំនុចអប្បបរមាដែលចាំបាច់
- តម្រូវឱ្យមានតម្លាភាពអតិបរមាតាមដែលមានលទ្ធភាពធ្វើបាន
- ធានាឱ្យមានការចូលរួមរបស់ភាគីពាក់ព័ន្ធក្នុងដំណើការធ្វើសេចក្តីសម្រេច (យ៉ាងហោចណាស់ក្នុងកម្រិតផ្តល់គំនិតធាតុចូល និងយោបល់ត្រឡប់វិញ)
- បង្កើតនូវនីតិវិធី និងលក្ខណៈវិនិច្ឆ័យមានតម្លាភាពនិងគណនេយ្យភាព។

- យើងត្រូវនាំគ្នាគ្រប់គ្រងលើអំណាចឆន្ទានុសិទ្ធិ និងជាពិសេសលើអំពើពុករលួយ តាមរយៈច្បាប់ដែលតាក់តែងឡើងក្នុងបេះដូងនៃអភិបាលកិច្ចល្អ។

# ចំណោទបញ្ហា

ការលុបបំបាត់អំណាចឆន្ទានុសិទ្ធិ មិនមែនជាជម្រើសសមស្របគ្រប់ស្ថានភាពទេ។ ដូច្នេះ តើត្រូវផ្តល់អំណាចឆន្ទានុសិទ្ធិដោយរបៀបណា ដើម្បីគ្រប់គ្រង និងធានាថា មន្ត្រីប្រើប្រាស់ឆន្ទានុសិទ្ធិតែក្នុងករណីបម្រើប្រយោជន៍សាធារណៈ?

# ច្បាប់អាចគ្រប់គ្រង**ឆន្ទានុសិទ្ធិ**បាន

តាមរយៈការថែងបញ្ជាក់អំពី

i. ប្រភេទនៃសេចក្តីសម្រេចដែលមន្ត្រីអាចធ្វើបាន
ii. កត្តាទាំងឡាយដែលមន្ត្រីអាចយកមកពិចារណាក្នុងការធ្វើសេចក្តីសម្រេច និង
iii. នីតិវិធីដែលមន្ត្រីត្រូវប្រើក្នុងការសម្រេច។

**ទិចនិកកម្រិតនូវឆន្ទានុសិទ្ធិ (ដោយកំណត់លក្ខខណ្ឌចំពោះអ្នកធ្វើសេចក្តីសម្រេច)**

(១) ចែងបញ្ជាក់ថានរណាខ្លះដែលអាចផ្តល់នូវគំនិតយោបល់ជាធាតុចូល

- ចែងបញ្ជាក់ពីប្រភេទធាតុចូលដែលអ្នកធ្វើសេចក្តីសម្រេចអាចទទួលយកធ្វើជាភស្តុតាង ឬ ជាសំអាងបាន
- តម្រូវឱ្យផ្តល់ហេតុផលជាលាយល័ក្ខណ៍អក្សរសម្រាប់សេចក្តីសម្រេចនោះ
- ចែងបញ្ជាក់កត្តាដែលមន្ត្រីត្រូវពិចារណាក្នុងដំណើការបំលែងធាតុចូលទៅក្នុងសេចក្តីសម្រេច (conversion process)។

(២) តម្រូវឱ្យមានសេចក្តីថ្លែងអំពីផលប៉ះពាល់ជាផ្នែកមួយនៃដំណើការបំលែងធាតុចូលទៅក្នុងសេចក្តីសម្រេច ។

(៣) ធ្វើសវនកម្មចំពោះសេចក្តីព្រាងច្បាប់លើចំណុចផ្តល់ ‘ឆន្ទានុសិទ្ធិ’។

# ទិចនិកសម្រាប់ធានានូវតម្លាភាព

(១) ពិនិត្យមើល និងប្រសិនបើចាំបាច់ ធ្វើកំណែទម្រង់លើច្បាប់ស្តីពីភាពសម្ងាត់នៃកិច្ចការផ្លូវការរបស់ប្រទេស (ឬ ច្បាប់ស្តីពីសិទ្ធិទទួលបានពត៌មានសាធារណៈ)

(២) ធានាឱ្យសាធារណជនមានសិទ្ធិអំណាច និងឱកាសត្រួតពិនិត្យមើលរាល់ឯកសារដែលរៀបចំឡើងក្រោមសេចក្តីព្រាងច្បាប់នោះ

(៣) ធានាឱ្យសាធារណជនមានសិទ្ធិ និងឱកាសចូលរួមសវនាការកិច្ចប្រជុំ និងដំណើការពិភាក្សាពិគ្រោះយោបល់ផ្សេងៗទៀតក្រោមសេចក្តីព្រាងច្បាប់នោះ

(៤) តម្រូវឱ្យមន្ត្រីធ្វើសេចក្តីសម្រេចជាលាយល័ក្ខណ៍អក្សរ និងបញ្ជាក់ពីហេតុផលនៃសេចក្តីសម្រេចនោះ។

# ទិចនិកធានានូវគណនេយ្យភាព

(១) គណនេយ្យភាពចំពោះថ្នាក់លើ

– តម្រូវឱ្យរាល់សេចក្តីសម្រេចជាលាយលក្ខណ៍អក្សរទាំងអស់មានផ្តល់ហេតុផល

– ផ្តល់សិទ្ធិឱ្យភាគីឯកជនមានសិទ្ធិប្តឹងទៅស្ថាប័នថ្នាក់លើ និងចុងក្រោយប្តឹងទៅតុលាការ

– ក្នុងករណីសមស្រប ផ្តល់នូវជំនួយផ្នែកច្បាប់ដល់បុគ្គល ឬ ក្រុមជនងាយរងគ្រោះ។

## (២) គណនេយ្យភាពចំពោះថ្នាក់ក្រោម (‘ការចូលរួម’)

– តម្រូវឱ្យមានភាគីពាក់ព័ន្ធចូលរួមច្រើនបំផុតតាមដែលអាចធ្វើបាន ដើម្បីផ្តល់គំនិតជាធាតុចូល និងមតិយោបល់ត្រឡប់វិញ ក្នុងដំណើការធ្វើសេចក្តីសម្រេចរបស់ស្ថាប័ន-ទីភ្នាក់ងារទទួលបន្ទុក
– ធានាថាស្ថាប័ន-ទីភ្នាក់ងារទទួលបន្ទុក ផ្តល់នូវពត៌មានគ្រប់គ្រាន់អំពីសភាពនៃបញ្ហាពាក់ព័ន្ធ ដើម្បីជួយឱ្យភាគីពាក់ព័ន្ធ ឬ តំណាងរបស់ពួកគាត់ អាចចូលរួមយ៉ាងមានប្រសិទ្ធភាព
– ធានាការចូលរួមរបស់តំណាងក្រុមជនងាយរងគ្រោះ (គ្រួសារក្រីក្រ ស្ត្រី ជនពិការ ចាស់ទុំ យុវវ័យ និងជនជាតិដើមភាគតិច) ក្នុងដំណើការធ្វើសេចក្តីសម្រេចរបស់ស្ថាប័ន-ទីភ្នាក់ងារទទួលបន្ទុក
– ប្រើស្មារក្តី ឬ អ្នកតស៊ូមតិសាធារណៈសម្រាប់ក្រុមជនងាយរងគ្រោះ ក្នុងដំណើការធ្វើសេចក្តីសម្រេចរបស់ស្ថាប័ន-ទីភ្នាក់ងារទទួលបន្ទុក។

# ការតាក់តែងច្បាប់ផ្អែកលើហេតុពិត និងឡូស៊ិក

សំណួរមួយសំណុំដែលត្រូវលើកឡើងតាំងពីដំបូង

- ឥរិយាបថអ្វីខ្លះគួរមានការកែប្រែ និងនរណាខ្លះ ដែលគួរផ្លាស់ប្តូរឥរិយាបទ?
- តើវាជាឥរិយាបថផ្អែកសង្គម វប្បធម៌ សេដ្ឋកិច្ច ឬនយោបាយ?
- តើវាជាឥរិយាបថរបស់បុគ្គល ឬ របស់ស្ថាប័ន?
- តើត្រូវការនូវការកែប្រែផ្លាស់ប្តូរលក្ខណៈដាច់ដោយដុំ ឬលក្ខណៈជាប្រព័ន្ធ?

- ហេតុអ្វីបានជាមនុស្សមានឥរិយាបថដូចដែលគេកំពុងប្រកាន់យកនៅចំពោះមុខច្បាប់? និយាយម៉្យាងទៀត តើមូលហេតុ ឬ កត្តាអ្វីដែលជំរុញឱ្យមនុស្សប្រកាន់នូវឥរិយាបថដែលមានបញ្ហាបែបនោះ?

# មូលហេតុ**ចម្បង** ៣ យ៉ាង ដែលផ្សារភ្ជាប់ទៅនឹងឥរិយាបថមានបញ្ហារបស់អ្នកកាន់តួនាទី (ភាគីពាក់ព័ន្ធ)

1. ពាក្យពេចន៍ក្នុងបទប្បញ្ញត្តិច្បាប់ ឬ វិធានច្បាប់ជាធរមាន (កត្តាលំបាកផ្នែកច្បាប់)
2. ឥរិយាបថរបស់ស្ថាប័ន-ទីភ្នាក់ងារអនុវត្ត ឬ និង ស្ថាប័នដាក់ឱ្យអនុវត្តនូវច្បាប់ ឬ វិធានច្បាប់
3. កត្តាក្រៅពីច្បាប់ និងកត្តាធនធានក្នុងមជ្ឈដ្ឋានរបស់អ្នកកាន់តួនាទី(ភាគីពាក់ព័ន្ធ)

- មូលហេតុបុគ្គល/អត្តនោម័ត (subjective) និង មូលហេតុគោលបំណង/សន្យានុម័ត (objective)។
- មូលហេតុលម្អិតចំនួន ៧ ដែលអ្នកតាក់តែងច្បាប់គួរមានការយល់ដឹង និងប្រើប្រាស់ ជាមូលដ្ឋានក្នុងការស្រាវជ្រាវដើម្បីរកឃើញនូវហេតុពិត និងឡូស៊ិក (ហេតុផលផ្តល់ដោយបទពិសោធន៍ពិត) ហៅថា <u>**សមាសធាតុ ៧ យ៉ាងនៃរបៀបវារៈស្រាវជ្រាវតាមទម្រង់ រ៉កស៊ីពី (ROCCIPI) ។**</u>

# រ៉កស៊ីពី ROCCIPI

- Rule វិធាន
- Opportunity ឱកាស
- Capacity សមត្ថភាព
- Communication of the Law ការប្រាស្រ័យទាក់ទងនៃច្បាប់
- Interest (Incentives) ផលប្រយោជន៍ (កត្តាលើកទឹកចិត្ត)
- Process ដំណើរការ
- Ideology (values/attitudes) មនោគមវិជ្ជា (គុណតម្លៃ/អាកប្បកិរិយា)

# រ៉កស៊ីពី (ROCCIPI)

- ***វិធាន* (*Rule*):** ជាកត្តាគោលបំណង/សន្សានុម័ត និងជាហេតុពន្យល់ដ៏សំខាន់អំពី ឥរិយាបទដែលមានបញ្ហា។
  – អ្នកតាក់តែងច្បាប់ ត្រូវមានការស្រាវជ្រាវ និងវិភាគលើវិធាន ឬ បទប្បញ្ញត្តិដែលមានស្រាប់ ដែលក្រោមវិធាននោះ អ្នកកាន់តួនាទី (ភាគីពាក់ព័ន្ធ) ប្រកាន់ ឥរិយាបទដែលមានបញ្ហា។
  – មានពាក្យពេចន៍ជាច្រើនក្នុងវិធានដែលមានស្រាប់ ដែលអនុញ្ញាត ឬ សម្រួលដល់ការប្រកាន់យកឥរិយាបទដែលមានបញ្ហានោះ ដោយសារពាក្យមិនច្បាស់លាស់។
  – វិធាននោះផ្តល់ឱ្យអ្នកកាន់តួនាទី ឬ ស្ថាប័ន-ទីភ្នាក់ងារអនុវត្ត ឬ ដាក់ឱ្យអនុវត្តវិធាននោះ នូវឆន្ទានុសិទ្ធដ៏ទូលំទូលាយដែលមិនមានលក្ខណៈចាំបាច់ ហើយប្រើពាក្យដែលពិបាកយល់ ធ្វើឱ្យក្រុមគោលដៅនៃច្បាប់នោះមិនអាចយល់អំពីខ្លឹមសាររបស់វាបាន។

- ***ឱកាស និងសមត្ថភាព*** *(Opportunity and Capacity)*: ជាកត្តាសន្យានុម័ត ចំនួរពីរទៀត និងក៏ជាហេតុពន្យល់ដ៏សំខាន់អំពី ឥរិយាបថដែលមានបញ្ហា។

អ្នកតាក់តែងច្បាប់ ត្រូវការធ្វើការប៉ាន់ស្មានអំពីជំនាញចំណេះដឹង និងលទ្ធភាពទទួលបានធនធាន ជាកត្តាដែលអាចមានឥទ្ធិពលលើឥរិយាបថរបស់អ្នកកាន់តួនាទី(ភាគីពាក់ព័ន្ធ)។

- ***ការប្រាស្រ័យទាក់ទងនៃច្បាប់*** (*Communication of the Law*)*:* ជាកត្តាសន្យានុម័ត មួយទៀត និងក៏ជាហេតុពន្យល់ដ៏សំខាន់ អំពី ឥរិយាបថដែលមានបញ្ហា។

អ្នកតាក់តែងច្បាប់ ត្រូវការចាំទុកថា

- លុះត្រាតែក្រុមគោលដៅ ដឹងអំពីអត្ថិភាព និងខ្លឹមសារនៃវិធានច្បាប់នោះ បើមិនដូច្នេះទេ ពួកគេគ្រាន់តែកែប្រែឥរិយាបទរបស់ខ្លួនស្របតាមវិធានច្បាប់នោះដោយចៃដន្យប៉ុណ្ណោះ
- ហើយលុះត្រាតែមាននរណាម្នាក់ប្រាស្រ័យទាក់ទងជាមួយក្រុមគោលដៅនៃច្បាប់អំពីវិធានច្បាប់នោះ បើមិនដូច្នេះទេពួកគេមិនដឹងថាមានវិធានច្បាប់នោះទេ។

- ***ផលប្រយោជន៍ (កត្តាលើកទឹកចិត្ត)*** Interest (Incentives)*:* ជាកត្តាអត្តនោម័ត ដែលអាចប្រើដើម្បីពន្យល់ពីឥរិយាបទដែលមានបញ្ហាបាន។ ឧទាហរណ៍ ការចង់ទទួលបាននូវកំណើនខាងសម្ភារៈទ្រព្យសម្បត្តិ បង្ករឱ្យមានឥរិយាបថពុករលួយ។ កត្តានេះក៏អាចផ្តល់សេចក្តីពន្យល់សម្រាប់ឥរិយាបទជាច្រើនបាន ប៉ុន្តែមិនមែនអាចពន្យល់នូវរាល់ឥរិយាបថទាំងអស់របស់មនុស្សទេ។ វាមិនសូវជួយដល់ការស្វែងរកនូវសម្មតិកម្មនៃហេតុ និងអំពើទេ (causal hypotheses)។

- ***ដំណើការ (Process):*** ជាកត្តាសន្យានុម័ត មួយទៀត និងមានប្រយោជន៍ក្នុងការពន្យល់អំពីឥរិយាបថដែលមានបញ្ហា។

វាជាកត្តាសម្រាប់ឱ្យក្រុមគោលដៅនៃវិធានច្បាប់នោះធ្វើការសម្រេចចិត្តថាពួកគេនឹងគោរពតាមវិធានច្បាប់នោះឬអត់។

កត្តាដំណើការនេះមានទំនោរបង្កបង្កើតនូវសម្មតិកម្មមានប្រយោជន៍ និងគួរឱ្យចាប់អារម្មណ៍ ជាពិសេសនៅពេលដែលក្រុមគោលដៅនៃវិធានច្បាប់គឺជាអង្គភាពចាត់តាំងសាំញ៉ាំ ដូចជា ក្រុមហ៊ុន សហជីព ឬ សហករ។

- លុះត្រាតែក្រុមគោលដៅ មានឱកាសចូលរួម (យ៉ាងហោចណាស់ក្នុងដំណើការប្រមូលនិងផ្តល់គំនិតជាធាតុចូល) ក្នុងការធ្វើសេចក្តីសម្រេចណាមួយ បើមិនដូច្នោះទេ សេចក្តីសម្រេចទាំងឡាយនោះប្រហែលជាមានលក្ខណៈអនាធិបតេយ្យ និងពុករលួយ។

- ***មនោគមវិជ្ជា (គុណតម្លៃ និងអាកប្បកិរិយា) Ideology (values and attitudes):*** ជាកត្តាអត្តនោម័ត មួយទៀត ដែលអាចប្រើដើម្បីពន្យល់ពីមូលហេតុជាច្រើន ប៉ុន្តែមិនមែនមូលហេតុទាំងអស់នៃឥរិយាបថរបស់មនុស្សបាន។
- ប្រសិនបើ ច្បាប់ទាមទារនូវឥរិយាបថដែលបំពានលើគុណតម្លៃរបស់អ្នកកាន់តួនាទី (ភាគីពាក់ព័ន្ធ) ករណីនោះពួកគេនឹងមិនគោរពច្បាប់នោះឡើយ
- ប្រសិនបើច្បាប់សម្របតាមគុណតម្លៃរបស់អ្នកកាន់តួនាទី (ភាគីពាក់ព័ន្ធ) ករណីនោះពួកគេនឹងប្រកាន់ឥរិយាបថបែបនោះដោយមិនចាំបាច់មានច្បាប់ទេ។

តើកត្តាទាំងនេះ មានកត្តាណាខ្លះដែលអ្នកគិតថាបិតក្នុងសមត្ថភាព និងការគ្រប់គ្រងរបស់អ្នកតាក់តែងច្បាប់នៅកម្ពុជា?

## 11. សំណួរផ្នែកនីតិរដ្ឋសម្រាប់ការតាក់តែងពិនិត្យផ្តល់យោបល់លើច្បាប់

(1) តើមានការផ្តល់សិទ្ធិអំណាចច្បាស់លាស់ក្រោមរដ្ឋធម្មនុញ្ញសម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ ឬ សេចក្តីស្នើច្បាប់នេះឬទេ?

(2) តើហេតុអ្វីបានជាត្រូវការមានច្បាប់នេះ? ហេតុអ្វីបានជាការធ្វើច្បាប់គឺជាការឆ្លើយតបដ៏ល្អបំផុតសម្រាប់ដោះស្រាយបញ្ហានោះ? តើមានកង្វល់ផ្នែកគោលនយោបាយអ្វីខ្លះដែលត្រូវបានកំណត់ឃើញថាគាំទ្រចំពោះតម្រូវការឱ្យមានច្បាប់ថ្មី? តើមានកំណត់ពន្យល់គ្រប់គ្រាន់សម្រាប់រាល់ផ្នែកសំខាន់ៗនៃសេចក្តីព្រាងច្បាប់ ឬ សេចក្តីស្នើច្បាប់ ឬទេ?

(3) តើសេចក្តីព្រាងច្បាប់ ឬ សេចក្តីស្នើច្បាប់នេះមាន អានុភាពបែបណាលើច្បាប់ទាំងឡាយដែលមានស្រាប់? តើសេចក្តីព្រាងច្បាប់ ឬ សេចក្តីស្នើច្បាប់នេះបានកំណត់ ជាក់លាក់នូវទំនាស់ ភាពមិនចាំបាច់ ឬ ការគងជាន់គ្នា ណាមួយ ដើម្បីអាចដកចេញនូវចំណុចដែលមិនមានភាព ច្បាស់លាស់ អំពីបូរណភាពផ្នែកច្បាប់នៃសេចក្តីព្រាង ច្បាប់ ឬសេចក្តីស្នើច្បាប់នេះ ឬទេ?

(4) តើសេចក្តីព្រាងច្បាប់ ឬ សេចក្តីស្នើច្បាប់នេះ កើតចេញពីកាតព្វកិច្ចរបស់កម្ពុជានៅថ្នាក់តំបន់ ឬ ថ្នាក់អន្តរជាតិ ឬមិនមែន? តើមានច្បាប់ដែលមានលក្ខណៈអាចប្រៀបប្រដូចគ្នាបាននៅក្នុងរដ្ឋសមាជិកអាស៊ានផ្សេងទៀតឬទេ? តើសេចក្តីព្រាងច្បាប់ ឬ សេចក្តីស្នើច្បាប់នេះ ពឹងផ្អែកមួយផ្នែក ឬ ទាំងស្រុង លើច្បាប់បរទេស ឬ ច្បាប់ទម្លាប់យុត្តិសាស្រ្តថ្នាក់តំបន់ ឬ ថ្នាក់អន្តរជាតិ ឬ? បើមិនមែនទេ ហេតុអ្វី? បើមែន តើមានបញ្ហាទាក់ទងនឹងការបកប្រែពាក្យច្បាប់ដែលត្រូវដោះស្រាយ ឬទេ?

(5) តើទម្រង់នៃសេចក្តីព្រាងច្បាប់ ឬ សេចក្តីស្នើច្បាប់នេះ គោរពតាមទម្លាប់អនុវត្តជាស្តង់ដាររួម ឬ ដែលណែនាំឱ្យប្រើ ឬទេ?

(6) តើច្បាប់នេះត្រូវបានសរសេរជាភាសាសាមញ្ញ ឬទេ? តើប្រជាពលរដ្ឋនឹងយល់ច្បាប់នោះ ឬទេ?

(7) តើច្បាប់នោះអាចអនុវត្តប្រតិសកម្ម ឬទេ?

(8) តើសេចក្តីព្រាងច្បាប់ ឬ សេចក្តីស្នើច្បាប់នេះ មានចែងច្បាស់លាស់អំពីទណ្ឌកម្ម និងទោសពិន័យ ចំពោះការខកខានក្នុងការគោរពអនុលោមតាមច្បាប់ឬទេ? តើមានលក្ខណៈសមហេតុផល ឬទេ? ស្រដៀងគ្នានេះដែរ តើឧបាស្រ័យអត្ថប្រយោជន៍ និងសិទ្ធិតវ៉ា ត្រូវបានកំណត់ច្បាស់លាស់ និងសមហេតុផលក្នុងស្ថានភាពផ្សេងៗគ្នា ឬទេ?

(9) តើរដ្ឋាភិបាលត្រូវបានចងកាតព្វកិច្ចដោយច្បាប់នេះឬទេ? ប្រសិនបើអត់ទេ ហេតុអ្វី?

(10) តើផលប៉ះពាល់នៃសេចក្តីព្រាងច្បាប់ ឬ សេចក្តីស្នើច្បាប់នេះលើក្រុមមនុស្សផ្សេងៗគ្នាត្រូវបានពិចារណាឬទេ? ផ្ទែកយេនឌ័រ? លើកុមារ? លើគ្រួសារ? លើអ្នកក្រីក្រ? លើអាជីវកម្មខ្នាតតូច និងមធ្យម?

(11) តើនរណានឹងធ្វើជាអ្នករដ្ឋបាលលើការអនុវត្តច្បាប់នេះ នៅពេលដែលវាត្រូវបានប្រកាសឱ្យប្រើប្រាស់? តើសិទ្ធិអំណាចរដ្ឋបាល និងគណនេយ្យភាពត្រូវបានកំណត់ច្បាស់ឬទេ?

(12) តើមានមន្ត្រីដែលទទួលបានការបណ្តុះបណ្តាលគ្រប់គ្រាន់គ្រប់ចំនួនសម្រាប់រដ្ឋបាលលើការអនុវត្តច្បាប់ថ្មីនេះឱ្យបានត្រឹមត្រូវ ឬទេ?

(13) តើច្បាប់នេះបង្កផលវិបាកផ្នែកចំណូលរដ្ឋ និងចំណាយលើការអនុវត្ត និងអនុលោមភាព ប៉ុណ្ណា? តើមានការបែងចែកធនធានគ្រប់គ្រាន់ទុកសម្រាប់អនុវត្តច្បាប់នេះឬទេ? តើមានច្រកណាដែលអាចនាំឱ្យមានអំពើពុករលួយក្នុងរដ្ឋបាលកិច្ច ឬ ការដាក់ឱ្យអនុវត្តសេចក្តីព្រាងច្បាប់ ឬ សេចក្តីស្នើច្បាប់នេះឬទេ?

(14) ប្រសិនបើតម្រូវឱ្យមានចេញអនុក្រឹត្យ ឬ លិខិតបទដ្ឋានគតិយុត្តផ្សេងទៀតសម្រាប់អនុវត្តច្បាប់នេះ តើសិទ្ធិអំណាចក្នុងការកំណត់ពីវិសាលភាព និងរយៈពេលអនុវត្តនៃលិខិតបទដ្ឋានគតិយុត្តទាំងនោះត្រូវបានចែងច្បាស់ឬទេ? ក្នុងករណីមានផលប៉ះពាល់កម្រិតខ្ពស់ តើសេចក្តីព្រាងអនុក្រឹត្យ ឬ លិខិតបទដ្ឋានគតិយុត្តនោះនឹងត្រូវផ្សព្វផ្សាយសម្រាប់ឱ្យមានការផ្តល់យោបល់មុននឹងអនុម័តឱ្យមានប្រសិទ្ធភាពអនុវត្តឬទេ? តើក្នុងពេលឆាប់ប៉ុណ្ណាក្រោយពេលប្រកាសឱ្យប្រើច្បាប់នេះ ដែលលិខិតបទដ្ឋានគតិយុត្តចាំបាច់សម្រាប់អនុវត្តច្បាប់ នឹងត្រូវបានរៀបចំរួចរាល់សម្រាប់ផ្សព្វផ្សាយ?

(15) តើមានក្តីកង្វល់អំពីការអប់រំជាសាធារណៈណាមួយ ទាក់ទងនឹងការផ្សព្វផ្សាយច្បាប់នេះដល់ក្រុមប្រជាពលរដ្ឋ និងអាជីវកម្មដែលរងផលប៉ះពាល់ដោយសារច្បាប់នេះឬទេ? ចុះមន្ត្រី និងតុលាការ នឹងធ្វើអ្វីដែរ? តើក្រសួងដែលផ្តួចផ្តើម ឧបត្ថម្ភលើការតាក់តែងច្បាប់នេះ មានផែនការអ្វីខ្លះក្នុងការ ជម្រាបដល់ប្រជាពលរដ្ឋអំពីសិទ្ធិ និងកាតព្វកិច្ចរបស់ពួក គាត់ក្រោមច្បាប់ថ្មីនេះ? តើក្រសួងនោះ ឬ រាជរដ្ឋាភិបាលត្រូវ បានតម្រូវក្នុងច្បាប់ឱ្យដាក់របាយការណ៍ប្រចាំឆ្នាំស្តីពីការអនុ វត្តច្បាប់នេះជូនសភាដែរឬទេ?

# 12. នីតិវិធីនៃការតាក់តែងច្បាប់របស់អង្គប្រតិបត្តិ

- សេចក្តីសង្ខេបនៃ សារាចរណែនាំ លេខ ០៣ (២០១៣) ស្តីពី នីតិវិធី និងវិធាននៃការតាក់តែងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត:
  - កំណត់នូវដំណើការធ្វើផែនការប្រចាំឆ្នាំសម្រាប់ការរៀបចំច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតដោយរាជរដ្ឋាភិបាល
  - កំណត់នីតិវិធីសម្រាប់ការតាក់តែងច្បាប់ ឬ ការពិនិត្យ និងផ្តល់យោបល់លើសេចក្តីស្នើច្បាប់
  - កំណត់វិធាន ឬ លក្ខខណ្ឌតម្រូវរបស់អង្គប្រតិបត្តិទាក់ទងនឹងទម្រង់នៃលិខិតូបករណ៍គតិយុត្តទាំងឡាយ។
- សូមមើលសេចក្តីលម្អិតនៃសារាចរណែនាំនេះ

# សំណួរ

- តើវិធានទាំងនេះត្រូវអនុវត្តចំពោះសេចក្តីស្នើច្បាប់ ដែរឬទេ?
- តើអង្គនីតិបញ្ញត្តិ ឬ អ្នកដែលជាមន្ត្រីអគ្គលេខាធិការដ្ឋាននៃរដ្ឋសភា ឬ ព្រឹទ្ធសភាត្រូវតែគោរពតាមសារាចរណែនាំនេះ ឬអត់? ហេតុអ្វី?

# សំណើប្លង់ និងទម្រង់នៃច្បាប់

1. ចំណងជើងសង្ខេបរបស់ច្បាប់
2. យោងសេចក្តី
3. សេចក្តីថ្លែងអំពីគោលដៅ និងគោលបំណងនៃច្បាប់
4. និយមន័យពាក្យគន្លឹះដែលប្រើក្នុងសេចក្តីព្រាងច្បាប់
5. ការបង្កើត ឬ ការកំណត់ទីភ្នាក់ងារ ឬ ការិយាល័យ ទទួលបន្ទុកអនុវត្តច្បាប់(បើវាជាផ្នែក១នៃច្បាប់)

4. ខ្លឹមសារនៃច្បាប់--រៀបបទប្បញ្ញត្តិសារវន្តតាមលំដាប់នៃភាពសំខាន់ ឬ លំដាប់លំដោយឡូសិក។ ជាធម្មតាដាក់បទប្បញ្ញត្តិកាតព្វកិច្ច មុនបទប្បញ្ញត្តិបណ្តោះអាសន្ន

5. ការហាមឃាត់ និងទោសបញ្ញត្តិ

6. បទប្បញ្ញត្តិផ្នែករដ្ឋបាល និងនីតិវិធី រួមទាំងសិទ្ធិអំណាចធ្វើវិធានទូទៅ ឬ ចេញលិខិតបទដ្ឋានគតិយុត្តដើម្បីអនុវត្តច្បាប់

9. បទប្បញ្ញត្តិដែលនិរាករច្បាប់ផ្សេងៗទៀត (ចូរជៀសវាង ឬប្រើប្រាស់ជាអប្បបរមានូវ *រាល់បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះត្រូវចាត់ទុកជានិរាករណ៍*)

10. បទប្បញ្ញត្តិវិសោធនកម្មលើច្បាប់ផ្សេងៗទៀតដើម្បីរក្សានូវបូរណភាព និងភាពស្របគ្នានៃច្បាប់ទាំងឡាយ

11. អន្តរប្បញ្ញត្តិ ប្រសិនបើមាន

12. កាលបរិច្ឆេទចូលជាធរមាន កាលបរិច្ឆេទអនុវត្ត (និងកាលបរិច្ឆេទផុតកំណត់ ប្រសិនបើមាន)។

# 13. របាយការណ៍ រ៉កស៊ីពី (ROCCIPI) សម្រាប់ការតាក់តែងច្បាប់

- របាយការណ៍ស្រាវជ្រាវសមស្រប ជួយដល់អ្នកតាក់តែងច្បាប់ ក្នុងការបំលែងគោលនយោបាយសេដ្ឋកិច្ច សង្គម វប្បធម៌ ឬ នយោបាយ ឱ្យទៅជាបទប្បញ្ញត្តិ ឬ ច្បាប់ដែលមានប្រសិទ្ធភាព។

# មុខងារនៃរបាយការណ៍ស្រាវជ្រាវ

- ផ្តល់សំអាងចំពោះសេចក្តីព្រាង ឬ សេចក្តីស្នើច្បាប់
- ជួយចង្អុលបង្ហាញដល់អ្នកតាក់តែងច្បាប់ក្នុងការសម្រេចអំពីភាពទ្បូស៊ិក និងហេតុពិត ដែលត្រូវការសម្រាប់ជាសំអាងចំពោះខ្លឹមសារលម្អិតសេចក្តីព្រាងច្បាប់ និង
- ជម្រាបដល់សមាជិកគណរដ្ឋមន្ត្រី និងដល់សមាជិកនីតិបញ្ញត្តិ។

# របាយការណ៍ស្រាវជ្រាវប្រើវិធីសាស្ត្រដោះស្រាយបញ្ហា

## ជំហាន ៤ យ៉ាងនៃវិធីសាស្ត្រនេះ

- កំណត់សភាព និងវិសាលភាពនៃបញ្ហាសង្គម
- ពន្យល់ពីមូលហេតុនៃឥរិយាបទដែលចូលរួមបង្ករជាបញ្ហាសង្គមនោះ
- កំណត់ដំណោះស្រាយនានាចំពោះបញ្ហាសង្គមនោះ – សំណើរក្នុងច្បាប់
- តាមដាន និងវាយតម្លៃអំពីផលប៉ះពាល់ផ្នែកសង្គមនៃច្បាប់នោះ។

# ប្រភពគំនិតសម្រាប់ការមានដំណោះស្រាយ

- ច្បាប់ និងបទពិសោធន៍របស់ប្រទេសផ្សេង
- ឯកសារដែលសរសេរដោយអ្នកមានវិជ្ជាជីវៈ
- បទពិសោធន៍កន្លងមករបស់ប្រទេសសាមី
- គំនិតយោបល់ផ្ទាល់របស់អ្នកតាក់តែងច្បាប់

## ល្អពីក្រៅស្អុយខាងក្នុង (បីសាចបិតក្នុងសេចក្ដីលម្អិត) The devil lies in the details

- តម្រូវឱ្យអ្នកតាក់តែងច្បាប់ ពន្យល់ខ្សោះក្បាយ អំពីជម្រើសទាំងឡាយ មុននឹងធ្វើការជ្រើសយកជម្រើសណាមួយ។

# ចំនុចដែលត្រូវពិចារណាមុននឹងចាប់ផ្តើមសរសេរវិធានលម្អិត

- តើសេចក្តីព្រាងច្បាប់នឹងប្រាប់ក្រុមគោលដៅ ឬ អ្នកកាន់តួនាទី(ភាគីពាក់ព័ន្ធ) ឱ្យធ្វើអ្វី?
- តើវិធានការលម្អិតអ្វីខ្លះដែលសេចក្តីព្រាងច្បាប់នឹងដាក់បញ្ចូល (រចនាសម្ព័ន្ធ និងដំណើការរបស់ស្ថាប័ន-ទីភ្នាក់ងារទទួលបន្ទុក ប្រភេទនៃសេចក្តីសម្រេច និងប្រព័ន្ធនៃការធ្វើវិធានច្បាប់)?
- តើមានវិធានការជំរុញឱ្យមានអនុលោមភាពអ្វីខ្លះដែលសេចក្តីព្រាងច្បាប់នឹងចែងតម្រូវឱ្យស្ថាប័ន-ទីភ្នាក់ងារអនុវត្តច្បាប់ប្រើក្នុងការបំពេញមុខងាររបស់ខ្លួន?

# ចំនុចដែលត្រូវពិចារណាមុននឹងចាប់ផ្តើមសរសេរវិធានលម្អិត

- តើផ្តល់ហិរញ្ញវត្ថុសម្រាប់ការអនុវត្តបទប្បញ្ញត្តិជាជម្រើស ផ្សេងៗទៀតដោយរបៀបណា? និង
- ស្ថាប័ន-ទីភ្នាក់ងារដោះស្រាយវិវាទ និងប្រភពថវិកាដែលត្រូវការសម្រាប់ជម្រើសនីមួយៗនៃដំណោះស្រាយ។

# វិធានការជំរុញឱ្យមានអនុលោមភាព

- **វិធានការចំៗ** គឺជារង្វាន់ និងការពិន័យទោស ដើម្បីកែប្រែនូវ ‵ផលប្រយោជន៍′ (ឬ កត្តាលើកទឹកចិត្ត) ដែលនាំឱ្យមានឥរិយាបទមានបញ្ហា។
- **វិធានការគៀងជុំ** គឺជាវិធានការទាំងឡាយសម្រាប់កែប្រែនូវមូលហេតុក្រៅពីកត្តាច្បាប់ ដែលនៅក្រៅខ្លួនរបស់តួអង្គ (ដូចជា ឱកាស សមត្ថភាព ការប្រាស្រ័យទាក់ទង ឬ ដំណើការ)។
- **វិធានការអប់រំ** គឺជាវិធានការទាំងឡាយដែលតាក់តែងឡើងដើម្បីកែប្រែនូវ ‵មនោគមវិជ្ជា′ – គុណតម្លៃ និងអាកប្បកិរិយាផ្ទាល់ខ្លួនរបស់តួអង្គ។

# ស្ថាប័នអនុវត្ត

- តុលាការ ឬ អង្គជំនុំជំរះក្តី
- ស្ថាប័ន-ទីភ្នាក់ងាររដ្ឋបាល (ក្រសួង នាយកដ្ឋាន ឬ អង្គភាពដាច់ដោយឡែក)
- សាជីវកម្មសាធារណៈ
- ការចុះកិច្ចសន្យាឱ្យក្រុមហ៊ុនឯកជនជាអ្នកអនុវត្ត។

តើជាប្រភេទស្ថាប័ន-ទីភ្នាក់ងារដែលដើរតួសកម្មឈានមុខ (proactive) ឬ រង់ចាំមានប្រតិកម្ម (reactive)?

តើជាស្ថាប័ន-ទីភ្នាក់ងារថ្មី ឬ គ្រាន់តែជាការផ្តល់សិទ្ធិអំណាច និងភារកិច្ចបន្ថែមជូនទីភ្នាក់ងារដែលមានស្រាប់?

# បុគ្គលិក ឬ មន្ត្រីអនុវត្តច្បាប់

- តើបុគ្គលិក ឬ មន្ត្រីទាំងឡាយត្រូវតែងតាំងឱ្យបម្រើការងារដោយរបៀបណា?
- តើពួកគាត់គួរមានលក្ខណៈសម្បត្តិគុណវុឌ្ឍិបែបណា? អាណត្តការងារ? លក្ខខណ្ឌសម្រាប់ការដកចេញពីមុខងារ?
- តើពួកគាត់គួរមានសិទ្ធិអំណាច និងភារកិច្ចអ្វីខ្លះ?

# 14. ទម្លាប់អនុវត្ត និងបញ្ហាប្រឈមនានាក្នុងការតាក់តែងច្បាប់នៅកម្ពុជាបច្ចុប្បន្ន

តាមការសង្កេតរបស់ខ្ញុំ ឃើញថាៈ

- ដឹកដោយអ្នកផ្តល់ជំនួយ និងការប្រាថ្នា លក្ខខណ្ឌ និងការប្រជែងគ្នារបស់អ្នកផ្តល់ជំនួយដើម្បីមានឥទ្ធិពលលើទម្លាប់អនុវត្ត និងប្រព័ន្ធច្បាប់កម្ពុជា (ដែលមានទស្សនទាន និងគោលការណ៍ច្បាប់ផ្សេងគ្នា ឬ ទំនាស់គ្នា)
- ធ្វើនិយ័តកម្មនូវទម្លាប់រដ្ឋបាលដែលមានស្រាប់ (ផ្អែកលើគំនិតរបស់អ្នកនយោបាយ)
- ពង្រីកអំណាច និងឆន្ទានុសិទ្ធិបែបការិយាល័យធិបតេយ្យ (ផ្អែកលើការប្រមូលផ្តុំអំណាច និងលើគំនិតរបស់អ្នកបច្ចេកទេស) នៅផ្នែកម្ខាង

- មានចក្ខុវិស័យលើផ្លូវដ៏វែងឆ្ងាយនូវអភិបាលកិច្ច និងការអភិវឌ្ឍបែបវិមជ្ឈការ (ផ្អែកលើទស្សនៈនៃការចែករំលែកអំណាច) នៅផ្នែកម្ខាងទៀត
- ការតាក់តែងជាលក្ខណៈដាច់ដោយដុំ vs. ការតាក់តែងជាលក្ខណៈប្រព័ន្ធ (ចំណុចបញ្ហា/ច្បាប់ជាក់លាក់មួយ vs. ការរៀបចំជាក្រុម)
- នៅតែមានលក្ខណៈអភិរក្ស conservative (vs. លក្ខណៈសេរី liberal)
- មានធ្វើច្បាប់បែបអីនទ្រេនស៊ីទីវ ច្រើនជាង ច្បាប់បែបទ្រេនស៊ីទីវ លើកលែងតែក្រមទាំងឡាយ

- មានទំនោរធ្វើច្បាប់ត្រួតត្រា និងហាមឃាត់ ជាជៀងច្បាប់ដែលបង្កបរិយាកាស និងផ្តល់សេរីភាពលើបញ្ហានយោបាយ ឬ យ៉ាងហោចណាស់ក្នុងដំណើការអនុវត្តដាក់ច្បាប់ឱ្យអនុវត្តដាក់ស្តែង
- កង្វះខាតធនធាន ឬ កង្វះការយល់ដឹងអំពីគោលនយោបាយដែលនៅពីក្រោយច្បាប់
- តួនាទីនៃឯកសារស្រាវជ្រាវគោលនយោបាយផ្អែកលើករណីជាក់ស្តែងក្នុងដំណើរការតាក់តែងច្បាប់ មិនទាន់មានការយល់ច្បាស់នៅឡើយ
- ជាញឹកញាប់ការតាក់តែងច្បាប់ចាប់ផ្តើមធ្វើឡើងជាភាសាបរទេសមួយ ឬច្រើន និងមានបញ្ហាផ្នែកបកប្រែ

- មានបទប្បញ្ញត្តិមិនច្បាស់លាស់ និងគងជាន់គ្នាច្រើន ហើយនឹងការប្រើប្រាស់ប្រកបដោយបញ្ហាក្នុងអវសានប្បញ្ញត្តិ ដែលចែងថា "បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះត្រូវទុកជានិរាករណ៍"
- កង្វះសមត្ថភាព និងយន្តការដាក់ឱ្យអនុវត្ត និងដោះស្រាយវិវាទប្រកបដោយប្រសិទ្ធភាព
- កង្វះថវិកា និងធនធានមនុស្សសម្រាប់ការអនុវត្ត និងការដាក់ឱ្យអនុវត្តមានប្រសិទ្ធភាព និងទាន់ពេលវេលា។